№ 47
23-12-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

******

ឆ្នាំទី ៥ លេខ ៤៧ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្តាហ៍

ក

មាតិកា

I_ខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រឹត្យ

២៨_១១_១៩៩៧	_ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៦២ តែងតាំងឯកឧត្តម ឧត្តមសេនីយត្រី **ណា សាំងហ៊ាង** ជាទីប្រឹក្សាផ្ទាល់របស់ ឯកឧត្តម **អ៊ុង ហួត**	២៦៧១
១៩_១២_១៩៩៧	_ព្រះរាជក្រឹត្យ នស/រកត/១២៩៧/៨២ តែងតាំងលោក **អ៊ឹក សុខុន** ជាឧកញ៉ា	២៦៧២
២២_១២_១៩៩៧	_ព្រះរាជក្រឹត្យ នស/រកត/១២៩៧/៨៣ តែងតាំង និង តម្លើងឋានៈជូនឯកឧត្តម **ឆន់ ចាយ** និងឯកឧត្តម **ដួងខែម** ជាទីប្រឹក្សារាជរដ្ឋាភិបាល	២៦៧៣

II_រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

១៦_១២_១៩៩៧	_អនុក្រឹត្យលេខ ៨២ អនក្រ/បក ស្តីពីការបង្កើតមន្ទីរការងារការបរទេស	២៦៧៤
១៨_១២_១៩៩៧	_អនុក្រឹត្យលេខ ៨៣ អនក្រ.បក ស្តីពីការផ្ទេរឥណទាន	២៦៧៦
១៨_១២_១៩៩៧	_អនុក្រឹត្យលេខ ៨៤ អនក្រ.បក ស្តីពីការផ្ទេរឥណទាន	២៦៧៨
១៨_១២_១៩៩៧	_អនុក្រឹត្យលេខ ៨៥ អនក្រ.បក ស្តីពីការផ្ទេរឥណទាន	២៦៨០
១៩_១២_១៩៩៧	_អនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់	២៦៨២

១៨-១២-១៩៩៧ -អនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ២៧១០
១៦-១២-១៩៩៧ -អនុក្រឹត្យលេខ ២៥១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៧១៦
១៦-១២-១៩៩៧ -អនុក្រឹត្យលេខ ២៥២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៧១៨
១៦-១២-១៩៩៧ -អនុក្រឹត្យលេខ ២៥៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧១៩
១៦-១២-១៩៩៧ -អនុក្រឹត្យលេខ ២៥៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧២០
១៦-១២-១៩៩៧ -អនុក្រឹត្យលេខ ២៥៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧២១
១៧-១២-១៩៩៧ -អនុក្រឹត្យលេខ ២៥៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៧២៣
១៨-១២-១៩៩៧ -អនុក្រឹត្យលេខ ២៥៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧២៤
១៨-១២-១៩៩៧ -អនុក្រឹត្យលេខ ២៥៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧២៥

២-សេចក្តីសំរេច

១៦-១២-១៩៩៧ -សេចក្តីសំរេចលេខ ៥២ សសរ. ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យចំណូលថវិការរដ្ឋ ២៧២៦

៣_សារាចរណែនាំ

១៨_១២_១៩៩៧ _សារាចរណែនាំលេខ ០៧ សរណន ស្ដីពីការរៀបចំបែបបទស្នើសុំគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា ២៧២៩

៤_ប្រកាស

២៣_១២_១៩៩៧ _ប្រកាសលេខ ០២ប្រ.ក របស់សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ២៧៣២

III_ការងារបណ្ដាក្រសួង

១_ទីស្ដីការគណៈរដ្ឋមន្ត្រី

ប្រកាស

១៨_១២_១៩៩៧ _ប្រកាសលេខ ១៧២ ប្រក. ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៧៣៤
២២_១២_១៩៩៧ _ប្រកាសលេខ ១៧៤ ប្រក. ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៧៣៥

២_ទីស្ដីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

១៧_១២_១៩៩៧ _ប្រកាសលេខ ៣២០/៩៧ ពម.ប្រក ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៧៣៦
១៧_១២_១៩៩៧ _ប្រកាសលេខ ៣២១/៩៧ ពម.ប្រក ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៧៣៧

៣_ទីស្តីការរដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

ប្រកាស

១៦_១២_១៩៩៧ _ប្រកាសលេខ ៤១១ ប្រក.សក.ហវ ប្រការ ២ នៃប្រកាស
លេខ ៣៩១ ប្រក.សក.ហវ ចុះថ្ងៃទី ២៥_១១_១៩៩៧
ត្រូវចាត់ទុកជានិរាករណ៍ ២៧៣៨

៤_ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន កីឡា

ប្រកាស

១៩_១២_១៩៩៧ _ប្រកាសលេខ ៨៨២ អយក.ប្រក ស្តីពីការពង្រីក និងប្តូរ
ឈ្មោះអនុវិទ្យាល័យភ្នំពេញ ទៅជាវិទ្យាល័យ ហ៊ុនសែន
«ភ្នំពេញ» ស្ថិតនៅក្នុងសង្កាត់ភ្នំពេញ ខណ្ឌភ្នំពេញ
ក្រុងព្រះសីហនុ ២៧៣៩

១៩_១២_១៩៩៧ _ប្រកាសលេខ ៨៨៤ អយក.ប្រក ស្តីពីការពង្រីក និងប្តូរ
ឈ្មោះអនុវិទ្យាល័យ កំពង់ពោធិ៍ ទៅជាវិទ្យាល័យ ហ៊ុនសែន
«កំពង់ពោធិ៍» ស្ថិតក្នុងស្រុកកំពង់ពោធិ៍ ខេត្តស្វាយរៀង ២៧៤១

១៩_១២_១៩៩៧ _ប្រកាសលេខ ៨៨៥/៩៧ អយក.ប្រក ស្តីពីការបើកវិទ្យា
ល័យ «សុខាផល្លី» ឧបសម្ព័ន្ធ វិទ្យាល័យកំពង់ស្ពឺ ផ្តាច់ពី
វិទ្យាល័យ កំពង់ស្ពឺ ២៧៤៣

២២_១២_១៩៩៧ _ប្រកាសលេខ ៨៨៦/៩៧ អយក.ប្រក ស្តីពីការអនុញ្ញាត
អោយបោះពុម្ពសៀវភៅសិក្សាសង្គម «សំរាប់សិស្សថ្នាក់
ទី ៤» ២៧៤៥

៥_ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងសុខាភិបាល

ប្រកាស

១៧_១២_១៩៩៧ _ប្រកាសលេខ ៣៦/៩៧ សឧក្រ. ស្ដីពីការផ្សព្វផ្សាយពាណិជ្ជកម្មអំពីសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ២៧៤៦

៦_ទីស្ដីការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ប្រកាស

២៣_១២_១៩៩៧ _ប្រកាសលេខ ២១២ បទ.ប្រក ស្ដីពីការបង្កើតមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ក្រុងប៉ៃលិន ២៧៤៨

៧_រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្ដីសំរេច

១៨_១២_១៩៩៧ _សេចក្ដីសំរេចលេខ ៦៩៣ សសរ.មស.ក្រខ ស្ដីពីការបែងចែកនិស្សិតចំនួន ២៧នាក់ ដែលទើបបញ្ចប់ការសិក្សាពីបរទេស ២៧៤៩

I ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៦២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

ត្រាស់បង្គាប់

មាត្រា ១ .– តែងតាំងឯកឧត្តម ឧត្តមសេនីយ៍ត្រី **ណា សាំងហ៊ាង** ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម **អ៊ុង ហួត** ...ករដ្ឋមន្ត្រីទី ១ ទទួលបន្ទុកកិច្ចការសន្តិសុខ ដោយមានឋានៈស្មើនឹង **រដ្ឋលេខាធិការ** ។

មាត្រា ២ .– នាយករដ្ឋមន្ត្រីទី១ និងនា...មន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ...តាមសំរេច ។

មាត្រា ៣ .– ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ នស/រកត/១២៩៧/៨២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក អ៊ុក សុខុន

ជា

ឧកញ៉ា

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧

ព្រះហស្តលេខា

ហត្ថលេខានិងត្រា

នរោត្តម សីហនុ

* * * *

ព្រះរាជក្រឹត្យ នស/រកត/១២៩៧/៨៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពនៃរាជរដ្ឋាភិបាល
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ .– ត្រូវបានតែងតាំង និងដំឡើងឋានៈជូន :

១_ឯកឧត្តម ធន់ ចាយ អភិបាលខេត្តសៀមរាប ជាទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារទូទៅបន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើទេសរដ្ឋមន្ត្រី ។

២_ឯកឧត្តម ដួង ខែម អភិបាលខេត្តបន្ទាយមានជ័យ ជាទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារទូទៅបន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើទេសរដ្ឋមន្ត្រី ។

មាត្រា ២ .- នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៧

ព្រះហស្ថលេខា

នរោត្តម សីហនុ

* * * *

II រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

អនុក្រឹត្យ លេខ : ៨២ អនក្រ.បក

ស្តីពីការបង្កើតមន្ទីរអាវុធសារការបរទេស

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-យោងតាមសំណូមពរចាំបាច់

សំរេច

មាត្រា ១ .- ត្រូវបានបង្កើតនៅទីស្តីការគណៈរដ្ឋមន្ត្រី នូវមន្ទីរការងារការបរទេស ។

មាត្រា ២ .- មន្ទីរការងារការបរទេស ជាអង្គភាពថ្នាក់ស្មើនាយកដ្ឋាន ហើយត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានជំនួយការ ។

មាត្រា ៣ .- មន្ទីរការងារការបរទេសទទួលបន្ទុក ÷

-ការងារការបរទេសជាអាទិ៍ សំរបសំរួលការងារលើគ្រប់វិស័យដែលពាក់ព័ន្ធជាមួយចិន និងសាធារណរដ្ឋកូរ៉េ ។

-ប្រមូលផ្តុំទិន្នន័យ សិក្សាស្រាវជ្រាវ វាយតំលៃ និងសន្និដ្ឋានលើសកម្មភាពការងារ ដែលពាក់ព័ន្ធជាមួយចិន និងសាធារណរដ្ឋកូរ៉េ ដើម្បីលើកយោបល់ជូនប្រមុខរាជរដ្ឋាភិបាល ។

មាត្រា ៤ .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង-ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត **ហ៊ុន សែន**

* * * *

អនុក្រឹត្យលេខ ៖ ៨៣ អនក្រ.បក

ស្ដីពីការផ្ទេរឥណទាន

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេច នរោត្ដម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧.១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/ ១២៩៦/៣៧ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាល ស្ដីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក នៃច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧

-បានឃើញប្រកាសលេខ ០១ ប្រ.សហវ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីចំណាត់ថ្នាក់ចំណូល និងចំណាយថវិកាតាមប្រភេទជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤ និងប្រកាសស្តីពីការកែប្រែ និងបំពេញបន្ថែមជាបន្តបន្ទាប់មាន : លេខ ០២២ ប្រ.សហវ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៤ លេខ ០០៣ ប្រ.សហវ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ លេខ ៣២៣ ប្រក.សហវ.ថ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៥ លេខ ៣៣៦ ប្រក.សហវ.ថ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥ លេខ ០៧១ ប្រក.សហវ.ថ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៦ និងលេខ ៨០១ សហវ.ថ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៦

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សំរេច

មាត្រា ១ .- ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានពីជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងជួសជុលតូច) របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន ៣.៥០០ លានរៀល មកជំពូក ១១ ក្នុងវង់ថវិការបស់ក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ។

មាត្រា ២ .- ឥណទានក្នុងមាត្រា ១ ត្រូវបានអនុញ្ញាតអោយក្រសួងការពារជាតិប្រើប្រាស់ សំរាប់ ទូទាត់ថ្លៃប្រេងឥន្ធនៈជូនក្រុមហ៊ុន សូគីម៉ិច ។

មាត្រា ៣ .-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត **ហ៊ុន សែន**

* * * *

អនុក្រឹត្យ លេខ : ៨៤ អនក្រ.បក

ស្តីពីការផ្ទេរឥណទាន

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧.១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/ ១២៩៦/៣៧ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧

– បានឃើញប្រកាសលេខ ០១ ប្រ.សហវ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីចំណាត់ថ្នាក់ចំណូល និងចំណាយថវិកាតាមប្រភេទជំពូក ប្រការ កថាខណ្ឌ វាក្យខណ្ឌ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤ និងប្រកាសស្តីពីការកែប្រែ និងបំពេញបន្ថែមជាបន្តបន្ទាប់មាន : លេខ ០២២ ប្រ.សហវ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៤ លេខ ០០៣ ប្រ.សហវ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ លេខ ៣២៣ ប្រក.សហវ.ថ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥ លេខ ៣៣៦ ប្រក.សហវ.ថ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥ លេខ ០៧១ ប្រក.សហវ.ថ ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៩៦ និងលេខ ៨០១ សហវ.ថ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៦

– តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សំរេច

មាត្រា ១ .– ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទាន :

– ពីជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ចនិងវប្បធម៌) របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន ១.២៨០លានរៀល មកជំពូក ៣១ ក្នុងវង្វង់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ។

– ពីជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងជួសជុលតូច) របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន ៣.៥០០លានរៀល មកជំពូក ១១ ក្នុងវង្វង់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ។

មាត្រា ២ .– ឥណទានក្នុងមាត្រា ១ ត្រូវបានអនុញ្ញាតអោយទីស្តីការគណៈរដ្ឋមន្ត្រីប្រើប្រាស់ជំពូក ៣១ សំរាប់ឧបត្ថម្ភប្រជាជនខូចខាតផ្ទះសំបែង និងទ្រព្យសម្បត្តិក្នុងព្រឹត្តិការណ៍ថ្ងៃ ៥–៦ ខែ កក្កដា ឆ្នាំ ១៩៩៧ ជំពូក ១១ ទូទាត់បុរេប្រទានលើមុខចំណាយពិសេសរបស់រាជរដ្ឋាភិបាល ។

មាត្រា ៣ .– សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

អនុក្រឹត្យ លេខ : ៨៥ អនក្រ.បក

ស្តីពីការផ្ទេរឥណទាន

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧.១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/ ១២៩៦/៣៧ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧

–បានឃើញប្រកាសលេខ ០១ ប្រ.សហវ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីចំណាត់ថ្នាក់ចំណូល និងចំណាយថវិកាតាមប្រភេទជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤ និងប្រកាសស្តីពីការកែប្រែ និងបំពេញបន្ថែមជាបន្តបន្ទាប់មាន : លេខ ០២២ ប្រ.សហវ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៤ លេខ ០០៣ ប្រ.សហវ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ លេខ ៣២៣ ប្រក.សហវ.ថ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៥ លេខ ៣៣៦ ប្រក.សហវ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥ លេខ ០៧១ ប្រក.សហវ.ថ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៦ និងលេខ ៨០១ សហវ.ថ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៦

–តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សំរេច

មាត្រា ១ .– ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានពីជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) នៃថវិការដ្ឋចំនួន ១.០០០លានរៀល (មួយពាន់លានរៀលគត់) មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងជួសជុលតូច) ក្នុងវង្វង់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ។

មាត្រា ២ .– ឥណទានក្នុងមាត្រា ១ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ ដើម្បីចំណាយពិសេសរបស់រាជរដ្ឋាភិបាល ។

មាត្រា ៣ .–សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

* * * *

អនុក្រឹត្យ លេខ : ៨៦ អនក្រ.បក

ស្តីពីលិខិតអនុញ្ញាតសាងសង់

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៤ នស៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់
- តាមសំណើរបស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌និងវិចិត្រសិល្បៈ រៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

សំរេច

មាត្រា ១ .– រាល់រូបវន្តបុគ្គល ឬ នីតិបុគ្គល សាធារណៈ ឬ ឯកជន មានសិទ្ធិសាងសង់អគារលើដីដែលជាកម្មសិទ្ធិរបស់ខ្លួន ហើយសិទ្ធិសាងសង់នេះត្រូវបានទទួលការការពារដោយអនុក្រឹត្យនេះ ។ លិខិតអនុញ្ញាតសាងសង់ដែលត្រូវបានចេញអោយមុនការសាងសង់ជាគ្រឹះនៃភាពស្របច្បាប់របស់សំណង់ ។ ឯរបៀបសុំលិខិតអនុញ្ញាតសាងសង់មានអធិប្បាយនៅក្នុងវគ្គទី១ នៃអនុក្រឹត្យនេះ ។

ដើម្បីអោយប្រជាពលរដ្ឋ ជាពិសេសប្រជាជនក្រីក្រមានលំនៅដ្ឋានសម្រាប់រស់នៅ រាល់សំណង់តូចតាចធ្វើអំពីឈើ ឬ ស្លឹក រុក្ខជាតិនានា ពុំទាមទារអោយសុំលិខិតអនុញ្ញាតសាងសង់ឡើយ ស្របតាមបទបញ្ញត្តិដែលមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ។

ដើម្បីធានាសុខមាលភាពនៃសំណង់ និងសុវត្ថិភាពសាធារណៈ ព្រមទាំងដើម្បីការពារដីធ្លីសាធារណៈចាំបាច់ សំរាប់ធានាដល់ដំណើរការរៀបចំទីក្រុង និងតំបន់កសិកម្មល្អប្រសើរ បទបញ្ញត្តិទូទៅនៃសំណង់មានកំណត់អំពីសិទ្ធិ និងអំពីករណីយកិច្ចនៃប្រជាពលរដ្ឋ និងស្ថាប័នសាធារណៈ ក្នុងការសាងសង់សំណង់សាធារណៈ និងសំណង់ឯកជន ។

រាល់ការគោរពនូវបទបញ្ញត្តិដែលមានចែងក្នុងវគ្គទី២ នៃអនុក្រឹត្យនេះ នឹងត្រូវបានទទួលលិខិតអនុញ្ញាតសាងសង់ ។

បទបញ្ញត្តិទាំងនេះ ត្រូវយកមកអនុវត្តក្នុងពេលពុំទាន់មានប្លង់ប្រើប្រាស់ដីធ្លី និងប្លង់គោល អនុម័តដោយរាជរដ្ឋាភិបាល ។

បទបញ្ញត្តិនេះអាចនឹងបំពេញបន្ថែម ដើម្បីអោយស្របទៅស្ថានភាពមូលដ្ឋាន ដោយស្ថិតក្នុងបទបញ្ញត្តិសំណង់ជាក់ស្តែងក្នុងប្លង់ប្រើប្រាស់ដីធ្លីរបស់ខេត្ត–ក្រុង ។

អនុក្រឹត្យនេះមិនយកទៅអនុវត្ត លើសំណង់មានស្រាប់ដែលមានការអនុញ្ញាត ។ ចំពោះសំណង់មានស្រាប់ដែលគ្មានការអនុញ្ញាត ហើយដែលប៉ះពាល់យ៉ាងខ្លាំងក្លាដល់ប្រយោជន៍ ឬ សោភ័ណភាពសាធារណៈ ការរុះរើត្រូវសំរេចដោយរាជរដ្ឋាភិបាល ឬ តំណាងដែលបានទទួលសិទ្ធប្រទាន តាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ច ។

ជំពូកទី ១

លិខិតអនុញ្ញាតសាងសង់ និង លិខិតអនុញ្ញាតរុះរើ

ផ្នែក ១

ភាតព្វកិច្ចនៃលិខិតអនុញ្ញាតសាងសង់

មាត្រា ២ :_ សំណង់ដែលតម្រូវអោយមានលិខិតអនុញ្ញាតសាងសង់ជាមុន

រាល់ការសាងសង់ក្នុងទីក្រុង និងទីប្រជុំជន ត្រូវមានលិខិតអនុញ្ញាតសាងសង់ រាល់សំណង់ថ្មី សុទ្ធតែត្រូវមានលិខិតអនុញ្ញាតសាងសង់ ។

ការសាងសង់ឡើងវិញជាថ្មី ការពង្រីក និងការសង់បន្ថែមពីលើអគារដែលមានស្រាប់ ក៏សុទ្ធតែតម្រូវអោយមានលិខិតអនុញ្ញាតសាងសង់ដែរ ។

ការប្តូរទ្រង់ទ្រាយអគារដែលមានស្រាប់ ត្រូវមានលិខិតអនុញ្ញាតសាងសង់ បើអគារនេះកែប្រែ :

_ការប្រើប្រាស់របស់ផ្នែកអគារ

_ទិដ្ឋភាពនៃអគារ (Aspect des Bâtiments)

_ការធ្វើបង្គន់អនាម័យ និងការបន្តភ្ជាប់ទៅបំពង់លូ

_ការធ្វើអាងប្រព្រឹត្តកម្មទឹកកខ្វក់ តភ្ជាប់ទៅបំពង់លូ

_បង្កើនផ្ទៃក្រឡាកម្រាលសំណង់

_កន្លែងទទួលសាធារណជន (Locaux ouverts au public)

_ទំរង់ដី (ចាក់ដីបំពេញ ជីកយកដីចេញ ប្តូរប្រភេទដីស្រែចំការជាដីសាងសង់) ឬ ប៉ះពាល់ខ្លាំងដល់ទិដ្ឋភាពទីដ្ឋានណាមួយ ដូចជាលុបបំបាត់បឹង ឬ ប្រឡាយបង្ហូរទឹក ឬ ផ្នែកណាមួយនៃប្រព័ន្ធបង្ហូរទឹកចេញ ការកាប់ដើមឈើដែលមានស្រាប់ ។ល។

ការសាងសង់ ឬ ការកែទ្រង់ទ្រាយថបនភណ្ឌផ្សេងៗ ដែលអាចបង្កគ្រោះថ្នាក់ដោយអគ្គីភ័យ (ការដាក់ស៊ីទែនកន្លែងប្រេងឥន្ទនៈ រោងជាងដែលមានផលិតផលគ្រឿងផ្ទុះ កន្លែងទទួលសាធារណជន) ។ល។ ការ[illegible]ទ្រង់ទ្រាយអគារឧស្សាហកម្ម ការដាក់ចំណាំងផ្សាយពាណិជ្ជកម្ម ការដាក់អង់តែនទូរទស្សន៍ និងទូរ[illegible]

នាឡិកាប៉ោល ប៉ាណូស្រូបពន្លឺព្រះអាទិត្យ ក៏ដូចជារាល់គ្រឿងដទៃទៀតដែលបំពាក់ទៅនឹងអគារ ហើយស្ថិតនៅជិតមាត់ផ្លូវ ឬ តាំងចំទិសដែលគេអាចមើលឃើញ សាលា ក្រុង និងសាលាខេត្ត នឹងធ្វើការណែនាំដោយឡែក ។

មាត្រា ៣ .– សំណង់ដែលពុំចំណុះក្រោមលិខិតអនុញ្ញាតសាងសង់

–សំណង់ជាលំនៅដ្ឋានប្រជាពលរដ្ឋដែលស្ថិតនៅទីជនបទ ឬ តំបន់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក និងឆ្ងាយពីតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភ័ណ្ឌជាតិ តំបន់រក្សាទុកការពារដោយពុំគិតពីទំហំ ឬ សំភារៈសំណង់ប្រើប្រាស់ឡើយ ។

–ការជួសជុល និងថែរក្សាទាំងឡាយដែលមិនផ្លាស់ប្តូរទ្រង់ទ្រាយ ឬ ទិដ្ឋភាពសំណង់ លើកលែងតែការជួសជុលនោះអាចបណ្តាលអោយប៉ះពាល់ដល់អ្នកជិតខាង ។

–បណ្តាសំណង់ដូចខាងក្រោមនេះ ដោយគ្រាន់តែជូនដំណឹងអំពីគំរោងសាងសង់ទៅអាជ្ញាធរមូលដ្ឋាន ដូចតទៅ :

–ទីសក្ការៈបូជា

–សាលាសំណាក់សាធារណៈ

–បណ្តាការសិល្បៈរបស់រដ្ឋសំរាប់សេវាសាធារណៈ ដែលរដ្ឋជាម្ចាស់កិច្ចការ

ជំពូក ២

សមត្ថកិច្ច ដែលចេញលិខិតអនុញ្ញាតសាងសង់

មាត្រា ៤ .– សមត្ថកិច្ចរបស់សាលាខេត្ត និង សាលាក្រុង

៤.១ ខេត្ត–ក្រុង មានសមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាតសាងសង់ ក្រោមការទទួលខុសត្រូវរបស់ខ្លួន ។

៤.២ លិខិតអនុញ្ញាតសាងសង់ ត្រូវបានចុះហត្ថលេខាដោយប្រតិភូរាជរដ្ឋាភិបាលប្រចាំទីក្រុង ឬ ដោយអភិបាលខេត្ត–ក្រុង ឬ អភិបាលរងដែលបានទទួលសិទ្ធិប្រទាន។ រាល់ការបដិសេធមិនផ្តល់លិខិតអនុញ្ញាតសាងសង់ ត្រូវមានការបញ្ជាក់ជាលាយលក្ខអក្សរនូវមូលហេតុច្បាស់លាស់ ។

មាត្រា ៥ ._ សមត្ថកិច្ចរបស់រាជរដ្ឋាភិបាល

៥.១ មានលិខិតអនុញ្ញាតសាងសង់មួយចំនួន ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលមានសមត្ថកិច្ចសំរេច ផ្តល់លិខិតអនុញ្ញាតសាងសង់ ចំពោះប្រភេទសំណង់ដូចតទៅ :

_បណ្តាអគារមានឧបនិស្ស័យខាងពាណិជ្ជកម្ម និង ឧស្សាហកម្ម ដែលមានផ្ទៃក្រឡាកម្រាលលើសពី ៣.០០០ ម៉ែត្រទ្វេគុណ ។

_រាល់សណ្ឋាគារ ត្រូវចាត់ទុកជាអគារមានឧបនិស្ស័យខាងពាណិជ្ជកម្ម ។

_បណ្តាអគារសំរាប់ការបង្កបង្កើនផលកសិកម្ម សំរាប់ធ្វើអាជីវកម្មពី ៥០០ ហិកតាឡើងទៅ ។

_បណ្តាអាកាសយានដ្ឋាន កំពង់ផែ ស្ថានីយអយស្ម័យយាន និងស្ថានីយ៍រថយន្ត ។

_បណ្តាសំណង់សាធារណៈ និងឯកជន ដែលមានផ្ទៃក្រឡាកម្រាសលើសពី ៣.០០០ម៉ែត្រទ្វេគុណ និងផ្នែកពង្រីកបន្ថែមដោយគិតទាំងអគារមានស្រាប់ ដែលលើសពី ៣.០០០ម៉ែត្រទ្វេគុណ (វប្បធម៌ អប់រំកីឡា រដ្ឋបាល ទេសចរណ៍ សុខាភិបាល ថាមពលទឹក....) ។

_បណ្តាសំណង់សំខាន់ៗក្នុងទីដ្ឋានការពារ និងក្នុងក្របខ័ណ្ឌបរិស្ថាន ទេសភាពបេតិកភ័ណ្ឌ ប្រវត្តិសាស្ត្រ បូរាណវត្ថុ និង វប្បធម៌ ។

_ការកែប្រែបណ្តាអគារ ជាផលប្រយោជន៍បេតិកភ័ណ្ឌដែលបានកំណត់ទុក ។

_បណ្តាសំណង់លើទីដីក្នុងភាពមើលឃើញទៅវិញទៅមក ជាមួយប្រាង្គប្រាសាទប្រវត្តិសាស្ត្រ ។

_បណ្តាសំណង់ និងការ៉ូ សំរាប់ការពារ និងអាគារយោធា ។

៥.២ ក្នុងករណីនេះ លិខិតអនុញ្ញាតសាងសង់ ត្រូវចុះហត្ថលេខា ដោយប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ បន្ទាប់ពីបានទទួលយោបល់ពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

មាត្រា ៦ ._ គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់របស់សាលាខេត្ត ឬ សាលាក្រុង

៦.១ សមត្ថកិច្ច

អនុលោមតាមមាត្រា ១៨ នៃច្បាប់រៀបចំទឹកដី នគរូបនីយកម្មនិង សំណង់ គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់មួយ ត្រូវបានបង្កើតឡើងក្នុង ពេលពុំទាន់មានប្លង់ប្រើប្រាស់ដី-ធ្លី និងសំណង់ ។ គណៈកម្មការនេះ ត្រូវដឹកនាំដោយប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ឬ អភិបាលខេត្ត ។

គណៈកម្មការនេះពិនិត្យរាល់សំណុំលិខិតសុំអនុញ្ញាតសាងសង់ ។

ចំពោះលិខិតអនុញ្ញាតសាងសង់ ដែលជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ក្រោយពីគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ ពិនិត្យសំណុំលិខិតហើយ ប្រតិភូរាជរដ្ឋាភិបាលប្រចាំទីក្រុង និងអភិបាលខេត្ត-ក្រុង បញ្ជូនរបាយការណ៍ និងយោបល់ទៅគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ ដើម្បីសំរេច ។

៦.២ សមាសភាពរបស់គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ :

គណៈកម្មការមានសមាសភាពដូចតទៅ :

- ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ឬ អភិបាលខេត្ត ជាប្រធាន
- មន្ទីរ សុរិយោដី សមាជិក
- មន្ទីរ រៀបចំក្រុងនិងសំណង់ ឬ ការិយាល័យសំណង់ ក្នុងករណីដែលគ្មាន សមាជិក
- មន្ទីរ សាធារណការ សមាជិក
- មន្ទីរ បរិស្ថាន សមាជិក
- មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ សមាជិក
- តំណាងស្ថាប័នពាក់ព័ន្ធទៅលើគំរោងសំណង់នោះ សមាជិក
- ការិយាល័យ (មូលដ្ឋាន) កិច្ចការនគរូបនីយកម្ម សមាជិក

គណៈកម្មការមានសិទ្ធិកោះអញ្ជើញដើម្បីសាកសួរ ឬ ស្តាប់រាល់បុគ្គលដែលបានដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ និងម្ចាស់កម្មសិទ្ធិ បើម្ចាស់កម្មសិទ្ធិនោះពុំមែនជាអ្នកដាក់ពាក្យសុំ នៅពេលដែលសំណុំលិខិតអនុញ្ញាតសាងសង់នោះបានចុះបញ្ជីជាផ្លូវការរួចហើយ ។

ជំពូក ៣

ការពិនិត្យមើលលើការចេញលិខិតអនុញ្ញាតសាងសង់

មាត្រា ៧ .– គ្មានលិខិតអនុញ្ញាតសាងសង់ណាមួយ អាចចេញអោយបានទេ បើលិខិតអនុញ្ញាតសាងសង់នោះពុំគោរពតាមប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី (ក្នុងករណីដែលមានប្លង់ទាំងពីរនេះ) ឬ ប្រសិនបើពុំមានប្លង់ទាំងពីរនេះទេ នោះការអនុញ្ញាតត្រូវអនុវត្តតាមបទបញ្ញាទូទៅស្តីពីការប្រើប្រាស់ដីធ្លីវិញ ។

ជនទាំងឡាយដូចជា នីតិបុគ្គល សាធារណៈ ឬ ឯកជន ត្រូវគោរពវិធានការនេះជាចាំបាច់ ។

មាត្រា ៨ .– សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ចំពោះក្រុងភ្នំពេញ និងទីក្រុងដទៃទៀត ត្រូវដាក់នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (មន្ទីររៀបចំក្រុងនិងសំណង់) ហើយចំពោះខេត្ត ត្រូវដាក់នៅសាលាស្រុក ឬ សាលាខេត្ត (មន្ទីរសំណង់) ។ បង្កាន់ដៃទទួលពាក្យសុំលិខិតអនុញ្ញាតសាងសង់មួយ ត្រូវបានចេញអោយអ្នកសុំកាលណាសំណុំលិខិតពាក្យសុំមានគ្រប់គ្រាន់ហើយ ។

មាត្រា ៩ .– បណ្តាឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់

ពាក្យសុំលិខិតអនុញ្ញាតសាងសង់ ត្រូវធ្វើលើគំរូលិខិតជាផ្លូវការ ហើយត្រូវមានភ្ជាប់សំណុំលិខិត ដែលមានយ៉ាងតិចបំផុតនូវបណ្តាប្លង់ដូចបញ្ជាក់ខាងក្រោមនេះ ជា ១០ច្បាប់ បត់ទំហំ (២១×២៩,៧ស.ម) :

៩.១ វិញ្ញាបនបត្រស្គាល់ម្ចាស់អចលនវត្ថុ ឬ បណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់អចលនវត្ថុ ឬ លិខិតកាន់កាប់ដីជាបណ្តោះអាសន្ន ។

៩.២ សលាកបត្រដីឡូត៍ :

ប្លង់ដីនេះធ្វើឡើងដោយភ្នាក់ងារមន្ទីរសុរិយោដី ឬ ដោយវេខាគណិតឯកជន។ ប្លង់នេះត្រូវចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយអ្នកធ្វើ និងអនុម័តដោយមន្ទីរសុរិយោដី ។

នៅលើប្លង់នេះមានបញ្ជាក់អំពី :

_ទីតាំងនៃដីឡូត៍ដែលជាកម្មវត្ថុនៃពាក្យសុំ ទីតាំង នៃដីឡូត៍ដែលនៅជាប់គ្នា ផ្លូវចូលទៅដីឡូត៍នោះ ហើយនិងលក្ខណៈរបស់ផ្លូវនោះ (សាធារណៈ ឬ ឯកជន ឈ្មោះម្ចាស់កម្មសិទ្ធិ) ។

_ឈ្មោះ ឬ លេខ ផ្លូវធំ និង ផ្លូវតូច

_ផ្ទៃក្រឡាដីឡូត៍

_បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូត៍ (ទីតាំង និង កំពស់)

_បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូត៍ជាប់គ្នា ផ្ទៃបាត និងកំពស់ របស់វា

_មាត្រដ្ឋានប្លង់រង្វាស់ជ្រុង និងមុំនីមួយៗ ការកំណត់ទិស

_ចំណុចនីងថ្កល់សំរាប់ជាគោលសំគាល់កំពស់ ដែលបោះនៅលើដីឡូត៍

_បន្ទាត់ជួរតម្រង់ផ្លូវសាធារណៈ

៩.៣ ប្លង់ទីតាំងអគារក្នុងដីឡូត៍ :

មាត្រដ្ឋាន ១ : ២០០ (ឬ ១ : ៥០០ ក្រោយទទួលការយល់ព្រមពីបណ្តាមន្ទីរ ទទួលបន្ទុកដីឡូត៍ធំៗ) ។

នៅលើប្លង់នេះមានបញ្ជាក់អំពី :

_ការបោះទីតាំងនៃសំណង់ក្នុងដីឡូត៍ដែលជាកម្មវត្ថុនៃពាក្យសុំ ដោយមាន ការបញ្ជាក់អំពីចម្ងាយ ងអគារមួយឬច្រើន និងព្រំប្រទល់ដីឡូត៍ ហើយនិង ចម្ងាយទៅបណ្តាអគារនៅជិតខាងដែលមានស្រាប់ ។

_រាល់ការរៀបចំកែ នៃដីទំនេរ ដោយបញ្ជាក់ប្រភេទដីនិងដំណាំ មានស្រាប់ និងទៅអនាគត បណ្តាកន្លែងចតរថយន្ត និងរបង (កំពស់ និង ទីតាំង) ។

_បំពង់លូក្រៅអគារ (រូបធាតុ វិជ្ឈមាត្រ ចំណោត គីរិតកំពស់ រណ្តៅពិនិត្យ) រហូតដល់កន្លែងតភ្ជាប់ទៅបណ្តាញសាធារណៈ សំរាប់បណ្តាញទឹកស្អុយ និងសំរាប់ ទឹកស្អាត អាងបង្គន់អនាម័យ អណ្តូង ។

_ចំណុចនីងថ្កល់នៃកំពស់ដីឡូត៍ ក្រោយការងាររៀបចំហើយ ។

៩.៤ ប្លង់អគារគ្រប់គ្រាន់ : មាត្រដ្ឋាន ១ : ១០០

នៅលើប្លង់នេះមានបញ្ជាក់ពី

- គោលដៅប្រើប្រាស់ក្នុងបន្ទប់ និង ផ្ទៃក្រឡារបស់វា
- បណ្តាបន្ទប់អនាម័យ និងកន្លែងដាក់បំពង់លូ
- ចំពោះការរៀបចំទីតាំងឧស្សាហកម្ម : របៀបរៀបចំទីតាំងគ្រឿងយន្ត

៩.៥ ប្លង់ផ្នែកបណ្តាញក្រោមដីនានា និងអាងបង្គន់អនាម័យ មាត្រដ្ឋាន ១ : ១០០

៩.៦ ប្លង់មុខភាពនៃអគារ (façades) មាត្រដ្ឋាន ១ : ១០០

នៅលើបណ្តាប្លង់មុខភាពមានបង្ហាញអំពី :

- កំរិតកំពស់កំរាលនីមួយៗ កំរិតកំពស់ដីនៅជើងអគារ ដោយបញ្ជាក់កំរិតកំពស់ដីធម្មជាតិ ដីចាក់បំពេញ ឬ ដីជីកចេញ
- កំរិតកំពស់ដំបូល និង កំពូលដំបូល ឬ កំរិតកំពស់នៅពេលសង់ហើយនៃដំបូលតេរ៉ាស និងក្បាលជញ្ជាំង ។
- កំរិតកំពស់សង់ហើយនៃទ្រើងផ្កា
- សម្ភារៈសំរាប់មុខភាព (Matériaux de façade)

៩.៧ ប្លង់ពុះពីរយ៉ាងតិច មាត្រដ្ឋាន ១ : ១០០

នៅលើប្លង់ពុះមានការបង្ហាញនូវប្លង់មុខកាត់ ពុះមួយបង្ហាញអាងបង្គន់អនាម័យ ។

៩.៨ តារាងផ្ទៃក្រឡាមួយសំរាប់ជាន់នីមួយៗ

៩.៩ សលាកបត្រគណនាផ្ទៃក្រឡាកម្រាលដី និង សន្ទស្សន៍នៃការប្រើប្រាស់ ។

ចំពោះបណ្តាការផ្លាស់ប្តូរទ្រង់ទ្រាយ ពង្រីកទំហំ ពង្រីកតម្លើងលើ ប្លង់ត្រូវបង្ហាញរបៀបខុសពីគ្នាចំពោះផ្នែកមានពីមុន ការរុះរើ និងសំណង់គ្រោងធ្វើ ។

សាលាក្រុង និងសាលាខេត្តនីមួយៗ ត្រូវចេញសារាចរបញ្ជាក់អំពីខ្លឹមសារចាំបាច់ និងឯកសារបន្ថែមពាក់ព័ន្ធនឹងសំណុំលិខិតអនុញ្ញាតសាងសង់ ។

អាចអោយអ្នកសុំសាងសង់ផ្តល់បណ្តាលិខិតស្នាមបន្ថែម ដោយមូលហេតុផ្នែកធារាសាស្ត្រ ផ្នែកការពារប្រឆាំងធាតុរំខានគ្រប់ប្រភេទ ផ្នែកសណ្តាប់ធ្នាប់សាធារណៈ ការពារបេតិកភណ្ឌ និងទេសភាព ។

៩.១០ ក្រោយពីបានទទួលលិខិតអនុញ្ញាតសាងសង់ហើយ ត្រូវមានបង្គោលអឹតគ្រឿងផ្គុំសំណង់ ដែលត្រូវពិនិត្យដោយក្រសួងសាធារណការ និងដឹកជញ្ជូនមុនបើកការដ្ឋានសាងសង់ ។

មាត្រា១០ ._ភាសាផ្លូវការ

សំណុំលិខិតពាក្យសុំលិខិតអនុញ្ញាតសាងសង់ទាំងអស់ ត្រូវជាភាសាខ្មែរ ។ អត្ថបទជាភាសាអង់គ្លេស ឬ បារាំងអាចផ្តល់ភ្ជាប់ជាមួយនឹងលិខិតនេះ ។

មាត្រា១១ ._ហត្ថលេខាលើពាក្យសុំ

ពាក្យសុំលិខិតអនុញ្ញាតសាងសង់ និងបណ្ណាប្លង់ ត្រូវចុះហត្ថលេខាដោយម្ចាស់ដី និងអ្នកធ្វើគំរោង ។

កាលណាអ្នកសុំពុំមែនជាម្ចាស់កម្មសិទ្ធិ អ្នកសុំដែលបានទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ ក៏ត្រូវចុះហត្ថលេខាលើសំណុំលិខិតពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ដែរ។

អ្នកធ្វើគំរោងត្រូវតែជាស្ថាបត្យករខ្មែរ ឬ បុគ្គលមានការរួមចំណែកជាមួយស្ថាបត្យករខ្មែរ ហើយដែលត្រូវបានទទួលស្គាល់ពីរាជរដ្ឋាភិបាល ស្នើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច ឬ ដោយគណៈស្ថាបត្យករ បន្ទាប់ពីគណៈស្ថាបត្យករខ្មែរនេះ ត្រូវបានបង្កើតឡើង ។

ក្នុងករណីដែលសំណង់មានទំហំលើសពី ៥០០ ម៉ែត្រក្រេទ្វេគុណ គំរោងអាចធ្វើបានដោយស្ថាបត្យករតែប៉ុណ្ណោះ ។

មាត្រា១២ ._ការផ្សព្វផ្សាយលិខិតអនុញ្ញាតសាងសង់ និងអង្កេតសាធារណៈ

អាជ្ញាធរមានសមត្ថកិច្ចផ្សព្វផ្សាយដំណឹងដល់សាធារណជន អំពីការដាក់ពាក្យសុំដោយបិទប្រកាសផ្សាយនៅសាលាខណ្ឌ ស្រុក ខេត្ត និងនៅកន្លែងសាងសង់គំរោង ។

កាលបរិច្ឆេទជាផ្លូវការនៃការដាក់ពាក្យស្នើសុំ ត្រូវចារក្នុងសំណុំលិខិត ហើយជូនដំណឹងដល់អ្នកសុំ ។ ម៉្យាងទៀតចំពោះអគារ និងបណ្តាគារធំៗ ឬ ដែលមានប្រភេទអាចធ្វើអោយខាតដល់សុវត្ថិភាព សុខមាលភាពសាធារណៈនោះ ត្រូវផ្សព្វផ្សាយដល់សាធារណជន ពីការដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ដោយវិធីណា

មួយផ្សេងទៀត ដែលគេយល់ឃើញថាមានប្រសិទ្ធភាពជាង ដោយផ្អែកលើមធ្យោបាយផ្សាយពត៌មាននៅតាមមូលដ្ឋាន ។

ប្រកាសមួយរបស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ កំណត់បញ្ជីអគារ និងការងារដែលពាក់ព័ន្ធ ។

រាល់បុគ្គលពាក់ព័ន្ធអាចសាកសួរសុំមើលសំណុំលិខិត នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (មន្ទីររៀបចំក្រុងនិងសំណង់) ចំពោះក្រុងភ្នំពេញ និងសាលាស្រុក ឬ សាលាខេត្ត (មន្ទីរសំណង់) ចំពោះខេត្តក្នុងរយៈពេល ២៥ថ្ងៃ និងអាចធ្វើការតវ៉ា ឬ ទាមទារទៅអាជ្ញាធរមានសមត្ថកិច្ច ។

បណ្តឹងតវ៉ាទាំងនេះត្រូវដាក់បញ្ចូលទៅក្នុងសំណុំលិខិតពាក្យសុំ ។

អាជ្ញាធរមូលដ្ឋានពិនិត្យមើលការជំទាស់ ដែលទទួលបានក្នុងពេលអង្កេត និងធ្វើរបាយការណ៍មួយជូនទៅសាលាខេត្ត សាលាក្រុង ក្នុងរយៈពេល ៥ថ្ងៃ ។ សាលាខេត្ត សាលាក្រុង ឬ គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) គណៈកម្មការនេះត្រូវសំរេចអំពីសុពលភាពនៃបណ្តឹងតវ៉ា ។

មាត្រា១៣ –អង្កេតនៅតាមបណ្តាមន្ទីរមានសមត្ថកិច្ច

គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) ឬ ក្នុងករណីផ្សេងទៀត មន្ទីររៀបចំក្រុង និងសំណង់ នៃបណ្តាខេត្ត–ក្រុង ប្រមូលយោបល់ពីមន្ទីរមានសមត្ថកិច្ច ហើយធ្វើសំយោគមួយ ។

យោបល់ និងសំយោគទាំងនោះជាលាយលក្ខអក្សរ ត្រូវដាក់ជូនអភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងពិនិត្យ និងសំរេច ។

បណ្តាមន្ទីរដែលត្រូវចូលរួមពិភាក្សាជាចាំបាច់ ក្នុងពេលពុំទាន់មានគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់រួមមាន ÷

–មន្ទីរសាធារណការ

–មន្ទីររៀបចំក្រុងនិងសំណង់

–មន្ទីរសាធារណការ

–មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ

–មន្ទីរហិរញ្ញវត្ថុ

–មន្ទីរបរិស្ថាន

និងកំណត់ស្តង់ដាកំណត់ពិនិត្យ

មាត្រា១៤ .– រយៈពេលពិនិត្យសំណុំលិខិត

រយៈពេលសំរាប់ពិនិត្យសំណុំលិខិតអនុញ្ញាតសាងសង់ ត្រូវបានកំណត់ត្រឹម ៤៥ថ្ងៃធ្វើការ ។ រយៈពេលនេះគិតចាប់ពីថ្ងៃដែលរាល់លិខិតស្នាមភ្ជាប់ជាមួយនឹងពាក្យសុំលិខិតអនុញ្ញាតសាងសង់បានបំពេញសព្វគ្រប់ ។ នៅចុងរយៈពេលកំណត់នេះ អ្នកស្នើសុំត្រូវបានទទួលដំណឹងអំពីសេចក្តីសំរេច ស្តីពីការអនុញ្ញាត (ឬការមិនអនុញ្ញាត) ឬ មួយការអនុញ្ញាតដែរ តែស្នើសុំអោយកែសំរួលបន្ថែម ។

ក្នុងករណីគ្មានចម្លើយណាមួយពីអាជ្ញាធរ នោះត្រូវចាត់ទុកបានចម្លើយជាវិជ្ជមាន ។

កាលបរិច្ឆេទថ្ងៃទី ១ នេះ ត្រូវបានកំណត់ដោយគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) ឬ ដោយមន្ទីររៀបចំក្រុងនិងសំណង់ ក្នុងករណីផ្សេងទៀត ។

បើអាជ្ញាធរមានសមត្ថកិច្ច បានស្នើដល់អ្នកសុំអោយធ្វើការកែប្រែតម្រូវនោះ រយៈពេល ៤៥ថ្ងៃធ្វើការថ្មីមួយទៀត នឹងត្រូវគិតចាប់ពីថ្ងៃដាក់ពាក្យសុំមានការកែតម្រូវជាថ្មីវិញ ។

ការបដិសេធផ្តល់លិខិតអនុញ្ញាតសាងសង់ និងការស្នើសុំអោយកែសំរួល ត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកសុំ ដោយអាជ្ញាធរមានសមត្ថកិច្ច ។

ជំពូកទី៤

នីតិវិធីបន្ទាប់ពីបានលិខិតអនុញ្ញាតសាងសង់

មាត្រា១៥ .– ការប្រគល់លិខិតអនុញ្ញាតសាងសង់

លិខិតអនុញ្ញាតសាងសង់ ត្រូវប្រគល់អោយអ្នកសុំដោយអាជ្ញាធរដែលបានអនុញ្ញាតអោយ ។

លិខិតអនុញ្ញាតសាងសង់មួយច្បាប់ អមដោយសំណុំលិខិតគ្រប់សព្វ (ប្លង់ លិខិតស្នាមជាឧបសម្ព័ន្ធយោបល់...) ត្រូវរក្សាទុកជាឯកសារជាប់ខាត ដោយសាលាខេត្ត ឬ សាលាក្រុង ។

ក្នុងករណីដែលលិខិតអនុញ្ញាតសាងសង់ ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល នោះគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ ត្រូវរក្សាទុកជាឯកសារ ១ច្បាប់ផងដែរ ។

មាត្រា១៦ .– លិខិតអនុញ្ញាតសាងសង់ផុតកំណត់កាល និងការងារបោះបង់ចោល

១៦.១ លិខិតអនុញ្ញាតសាងសង់អស់សុពលភាព បើការងារពុំដំណើរការក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាចេញលិខិតអនុញ្ញាតសាងសង់ ។

លិខិតនេះ អាចអនុញ្ញាតពន្យារពេលបានមួយដង ។

សំណង់ដែលត្រូវទុកថាបានចាប់ផ្តើមសាងសង់ កាលណាជើងគ្រឹះត្រូវបានធ្វើហើយ ។

ចំពោះការសាងសង់បន្ថែមជាន់ ត្រូវចាត់ទុកថាបានចាប់ផ្តើម កាលណាសសរទីមួយត្រូវបានធ្វើហើយ ។

១៦.២ កាលណាការងារសាងសង់ត្រូវបានផ្អាកលើសពីមួយឆ្នាំ អាជ្ញាធរក្រុង ឬ ខេត្ត អាចបង្ខំអោយធ្វើមញ្ចប់ ឬ បង្ខំអោយរះរើសំណង់ដែលបានចាប់ផ្តើម និងអោយរៀបចំទីកន្លែងអោយបានត្រឹមត្រូវដូចដើមវិញ ក្នុងរយៈពេលមួយដែលបានកំណត់ និងដោយសោហ៊ុយរបស់ម្ចាស់លិខិតអនុញ្ញាតសាងសង់ ។

មាត្រា១៧ .– ការចាប់ដំណើរការការដ្ឋាន

ការដ្ឋាន ពុំត្រូវចាប់ដំណើរការមុនពេលបានទទួលលិខិតអនុញ្ញាតសាងសង់ និងមុនពេលទទួលបានការអនុម័តលើប្លង់លំអិតគ្រឿងផ្គុំសំណង់ឡើយ ។

រាល់សហគ្រិនទទួលបន្ទុកសាងសង់សំណង់ ត្រូវបញ្ជាក់អោយដឹងច្បាស់ថា លិខិតអនុញ្ញាតសាងសង់ត្រូវបានអនុញ្ញាតរួចហើយ ពីព្រោះជាប់ទទួលខុសត្រូវរួមជាមួយម្ចាស់សំណង់ ។

អ្នកកាន់លិខិតអនុញ្ញាតសាងសង់ ត្រូវតំកល់ទុកនៅការដ្ឋាន នូវសេចក្តីចម្លងឯកសារបដ្ឋានពីការចេញលិខិតអនុញ្ញាតសាងសង់មួយច្បាប់ សំរាប់មន្ទីរ ក្រុង ឬ ខេត្ត ត្រួតពិនិត្យ ។

ប្លង់អនុវត្តការសាងសង់ និងប្លង់លំអិតសំណង់មួយច្បាប់ ត្រូវតំកល់ទុកជាប្រចាំនៅការដ្ឋាន សំរាប់មន្ទីរ ក្រុង ឬ ខេត្ត ត្រួតពិនិត្យ ។

មាត្រា១៨ .–ដំណើរការទៅមុខនៃការងារ

១៨.១ ក្រោយពីបានទទួលលិខិតអនុញ្ញាតសាងសង់ និងប្លង់លំអិតគ្រឿងផ្គុំសំណង់ ហើយម្ចាស់សំណង់ត្រូវជូនដំណឹងទៅសាលាស្រុក–ខ័ណ្ឌ និងចុះទិដ្ឋាការនៅមន្ទីរមានសមត្ថកិច្ច ។

មុនចាប់ដំណើរការការដ្ឋាន ម្ចាស់សំណង់ត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានពីមន្ទីររៀបចំក្រុង និងសំណង់ ឬ ការិយាល័យខេត្ត–ក្រុង ។

ស្ថាប័នសមត្ថកិច្ចបច្ចេកទេស ត្រូវតាមដានការអនុវត្តន៍ជាជំហានៗដូចតទៅ :

–ក្រោយការបោះបង្គោលកំណត់ទីតាំងសំណង់

–ក្រោយការងារផ្នែកគ្រឹះ និងមុនការធ្វើកម្រាលក្រោមនៃជាន់ផ្ទាល់ដី

–នៅទីបញ្ចប់នៃការឫធំៗ (គ្រឹះ–សសរ–ជញ្ជាំង–កម្រាល...) ផ្នែកសំខាន់ៗនៃសំណង់

–នៅពេលតភ្ជាប់ទៅបណ្ដាញលូទឹកស្អុយ ទឹកស្អាត និងបណ្ដាញអគ្គិសនី

១៨.២ រាល់ការផ្លាស់ប្ដូរម្ចាស់សំណង់ ក្នុងពេលកំពុងដំណើរការសាងសង់ ត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច ។

មាត្រា១៩ .–ការរៀបចំការដ្ឋានសំណង់

ការដាក់គរសំភារៈសំណង់លើផ្លូវសាធារណៈត្រូវហាមឃាត់ :

–កាលណាសំណង់ត្រូវការកន្លែងតាំងការដ្ឋានលយទៅលើផ្លូវសាធារណៈ កន្លែងការនោះ ត្រូវកំណត់ត្រឹម២ម ទៅលើចិញ្ចើមផ្លូវ ។ កន្លែងនោះត្រូវធ្វើរបងហ៊ុំព័ទ្ធក្នុងរយៈពេលដំណើរការរបស់ការដ្ឋាន ។

–រាល់កន្លែងតាំងកា[illegible]រុះរើចេញក្នុងរយៈពេលមួយសប្ដាហ៍ ក្រោយពេលចប់ការដ្ឋាន ។

–គំនរសំភារៈ កាកសំណល់បានមកពីការរុះរើ ឬ ពីការសាងសង់ ឬ ការជួសជុលត្រូវយកចេញក្នុងរយៈពេលមួយសប្ដាហ៍ ក្រោយពេលចប់ការងារ ។

–ក្នុងករណីពុំបានរើយកសំភារៈកាកសំណល់ចេញពីកន្លែងតាំងការដ្ឋានទេ សាលាខ័ណ្ឌ ឬ សាលាស្រុកមានភារកិច្ច ចាត់ចែងដឹកជញ្ជូនចេញដោយស្វ័យប្រវត្តិ ។ ចំណាយជាបន្ទុករបស់ម្ចាស់សំណង់ ។

មាត្រា២០ .- ការត្រួតពិនិត្យ និង ការបញ្ឈប់ការងារ

អាជ្ញាធរក្រុង ឬ ខេត្ត អាចចូលមើល និងត្រួតពិនិត្យការដ្ឋានគ្រប់ពេលវេលា ហើយនិងពិនិត្យប្លង់ដែលបានអនុម័តរួច ។ បើពិនិត្យឃើញភាពមិនត្រឹមត្រូវ អាជ្ញាធរនោះជំរាបជាលាយលក្ខអក្សរទៅម្ចាស់សំណង់ ដោយកែតម្រូវក្នុងរយៈពេលកំណត់មួយ ។

ក្នុងករណីពុំបានអនុវត្ត ឬ បានអនុវត្តពុំត្រឹមត្រូវតាមបញ្ជា ការផ្អាកការងារត្រូវចេញបញ្ជាជាបន្ទាន់ដោយអាជ្ញាធរ ក្រុង ឬ ខេត្ត ។

សាលាក្រុង ឬ សាលាខេត្ត អាចប្តឹងទៅតុលាការមានសមត្ថកិច្ចអោយចេញដីកាកិច្ចការប្រញាប់ ដោយផ្អាកការសាងសង់ ឬ ផ្លាស់ប្តូរទ្រង់ទ្រាយសំណង់ដែលពុំត្រឹមត្រូវ ឬ គ្មានច្បាប់នោះ ។ ចំណាយជាបន្ទុករបស់ម្ចាស់សំណង់ ។

អនុលោមទៅតាមសភាពធ្ងន់ធ្ងរនៃការខុសឆ្គង បណ្តាសំភារៈ និងទព្វសំភារៈរបស់ការដ្ឋាន អាចត្រូវរឹបអូសតាមបង្គាប់តុលាការ ។

មាត្រា២១ .- វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ

អ្នកសុំលិខិតអនុញ្ញាតសាងសង់ ត្រូវប្រកាសប្រាប់អំពីការចប់ការងារ ដល់សាលាខណ្ឌ ឬ សាលាស្រុក ។

ពេលបញ្ចប់ការដ្ឋាន សាលាខណ្ឌ ឬ សាលាស្រុកជាមួយនិងការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (មន្ទីររៀបចំក្រុងនិងសំណង់) អាចត្រួតពិនិត្យភាពត្រឹមត្រូវស្របគ្នា រវាងសំណង់ដែលធ្វើរួចហើយ និងលិខិតអនុញ្ញាតសាងសង់ដែលបានចេញអោយ ។

ត្រូវចាត់ទុកថាពុំត្រឹមត្រូវ បើផ្ទៃបាតសំណង់ ឬ ផ្ទៃក្រឡាកម្រាលបានសាងសង់លើសពីកំរិតអនុញ្ញាត ។

អាចចាត់ទុកថាពុំត្រឹមត្រូវ បើទិដ្ឋភាពនៃអគារមានភាពងាយឃើញខុសគ្នា ពីលិខិតអនុញ្ញាតសាងសង់ដែលបានចេញអោយ ។

ក្នុងករណីពុំត្រឹមត្រូវទេ អាជ្ញាធរក្រុង ឬ ខេត្តអាចបង្ខំម្ចាស់សំណង់អោយកែតម្រូវអគារអោយបានត្រឹមត្រូវ ស្របគ្នានឹងលិខិតអនុញ្ញាតសាងសង់ដែលបានចេញអោយ ។

ក្នុងករណីពុំត្រឹមត្រូវ អាជ្ញាធរក្រុង ឬ ខេត្តអាចបង្ខំម្ចាស់សំណង់ អោយកែតម្រូវអគារអោយបានត្រឹមត្រូវស្របគ្នានឹងលិខិតអនុញ្ញាតសាងសង់ដែលបានចេញអោយ ។

ក្នុងករណីមិនគោរពតាមទេ សាលាក្រុង ឬ សាលាខេត្ត ត្រូវប្តឹងទៅតុលាការមានសមត្ថកិច្ចអោយចេញសាលក្រម ឬ សាលដីកា ។

វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវមួយ ដែលចេញអោយដោយអាជ្ញាធរក្រុង ឬ ខេត្តត្រូវតែមានជាចាំបាច់ខានពុំបាន ចំពោះបណ្តាអគារសំរាប់ទទួលសាធារណៈជនសណ្ឋាគារ ការិយាល័យ ក៏ដូចជាចំពោះបណ្តាកន្លែងធ្វើការរបស់អ្នកមានបៀវត្ស ។ វិញ្ញាបនបត្រនេះត្រូវបានទទួលមុនការបើកប្រើប្រាស់កន្លែងធ្វើការនោះ ។

វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវមួយ ចេញអោយដោយអាជ្ញាធរក្រុង ឬ ខេត្ត ត្រូវតែមានជាចាំបាច់ខានពុំបាន មុនពេលបើកអោយប្រើប្រាស់ចំពោះបណ្តាអគារដែលសាងសង់នៅក្នុងរមណីយដ្ឋាន និងទេសភាពធម្មជាតិ ឬ ក្រុង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ បុរាណសាស្ត្រ បេតិកភណ្ឌ ឬ នៅកន្លែងមើលឃើញទៅវិញទៅមកជាមួយនិងប្រាសាទប្រវត្តិសាស្ត្រណាមួយ ។

ជំពូក ៥

លិខិតអនុញ្ញាតរុះរើ

មាត្រា២២.– រាល់ម្ចាស់កម្មសិទ្ធិ ឬ អ្នកទទួលសិទ្ធិតំណាងក្នុងអាណត្តិ ដែលមានបំណងរុះរើអគារណាមួយដែលមានស្រាប់ ក្រៅពីសំណង់បណ្តោះអាសន្នមិនថិតថេរ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតរុះរើ នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ ។

សំណុំពាក្យសុំលិខិតអនុញ្ញាតរុះរើត្រូវមាន៖

ប្លង់ដីឡូត៍ និងប្លង់អគារ រូបថតអគារ ឬ ឯកសារផ្សេងៗទៀតដែលចាំបាច់ ។

ចំពោះរាល់អគារដែលមានចុះក្នុងបញ្ជីបេតិកភណ្ឌ ពាក្យសុំអនុញ្ញាតរុះរើត្រូវឆ្លងតាមគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ ហើយត្រូវបានអនុញ្ញាតដោយអភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ។

លិខិតអនុញ្ញាតរុះរើ ត្រូវផ្សព្វផ្សាយភ្លាមជាសាធារណៈ ដោយការបិទប្រកាសនៅកន្លែងដែលអាចមើលឃើញផ្លូវសាធារណៈ នៅកន្លែងគ្រោងធ្វើការរុះរើ ។ ការងាររុះរើ ពុំអាចចាប់ផ្តើមក្នុងរយៈពេលតិចជាង ១៥ថ្ងៃ បន្ទាប់ពីការចេញលិខិតអនុញ្ញាតឡើយ ។

លិខិតអនុញ្ញាតរុះរើ ត្រូវចាត់ទុកយល់ព្រម បើពុំមានចំលើយណាមួយក្រោយពីថ្ងៃដាក់ពាក្យសុំ ៣ខែ ។

រាល់ជំទាស់ ត្រូវផ្តល់ដំណឹងទៅអ្នកសុំជាលាយលក្ខអក្សរ ។

មាត្រា២៣.–បណ្តាបទបញ្ញាស្តីពីសមត្ថកិច្ច និងការពិនិត្យពាក្យសុំដែលអនុវត្តចំពោះលិខិតអនុញ្ញាតសាងសង់ ត្រូវអនុវត្តបានដូចគ្នាចំពោះពាក្យសុំលិខិតអនុញ្ញាតរុះរើ ។

ជំពូក ៦

បទល្មើស និង បណ្តឹងតវ៉ា

មាត្រា២៤ .–ករណីបទល្មើស

រាល់សំណង់ ដែលបានចាប់ផ្តើមដំណើរមុនចេញលិខិតអនុញ្ញាតសាងសង់ ដោយអាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់ទុកជាល្មើសច្បាប់ ។ ការដ្ឋានត្រូវបញ្ឈប់ជាបន្ទាន់ ។

បណ្តាបុគ្គល ដែលបានប្រព្រឹត្តល្មើសនឹងបញ្ជារបស់មន្ត្រី និងភ្នាក់ងាររបស់រាជការ ត្រូវជាប់ទោស ហើយឧបករណ៍ទាំងឡាយនៅក្នុងការដ្ឋានត្រូវរឹបអូស ។ ក្នុងករណីមិនរាងចាល ត្រូវពិន័យជាបទលហុ បើពុំព្រមបញ្ឈប់ការងារ ត្រូវបញ្ជូនជនល្មើសទៅតុលាការ ដែលត្រូវវិនិច្ឆ័យតាមច្បាប់ជាធរមាន ។

មាត្រា២៥ .–បណ្តឹងតវ៉ា

រាល់សេចក្តីសំរេចទាក់ទងនឹងពាក្យសុំលិខិតអនុញ្ញាតសាងសង់ មុនឡើងទៅតុលាការមានសមត្ថកិច្ចអាចជាកម្មវត្ថុនៃបណ្តឹងតវ៉ា ទៅអាជ្ញាធរមានសមត្ថកិច្ច ដូចបានបញ្ជាក់ក្នុងមាត្រា ៤ និង ៥ នៃអនុក្រឹត្យនេះ ដើម្បីធ្វើការពិនិត្យលើបណ្តឹងតវ៉ានេះ ។

អាជ្ញាធរមានសមត្ថកិច្ច មាននីតិសម្បទាសំរបសំរួលជាមួយម្ចាស់បណ្តឹង ។ ក្នុងករណីមិនបានសំរេច អ្នកប្តឹងអាចតវ៉ាទៅដល់ប្រធានគណៈកម្មាធិការជាតិរៀប

ចំទឹកដីនគរូបនីយកម្មនិងសំណង់ ហើយត្រូវមានមន្ត្រីតំណាងរាជរដ្ឋាភិ-
បាល
[illegible]ការងារនេះ ត្រូវមានមន្ត្រីតំណាងមួយនៅគ្រប់សាលាខេត្ត ឬ សាលាក្រុង និងក្នុងគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ ។

ផ្នែកទី ២

បទបញ្ញត្តិទៅនៃការប្រើប្រាស់ដី-ធ្លី

មាត្រា២៦.-បទបញ្ញត្តិទៅនៃការប្រើប្រាស់ដី-ធ្លីនេះ ត្រូវយកមកអនុវត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវអោយរាល់បុគ្គលសាធារណៈ ទីជ ឯកជន ជារូបវន្តបុគ្គលក្តី ឬ នីតិបុគ្គលក្តី គោរពប្រតិបត្តិតាមលិខិតអនុញ្ញាតសាងសង់ ក្នុងរយៈពេលដែលពុំទាន់មានប្លង់ប្រើប្រាស់ដី-ធ្លី នឹងប្លង់គោលនៅឡើយនោះ ។

ជំពូក ១

ប្រភេទ ការកំណត់ទីតាំង និង

ផ្លូវចេញចូលដល់ទីតាំងសំណង់

មាត្រា២៧.-សុវត្ថិភាព និងសុខមាលភាពសាធារណៈ

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះសំណង់ទាំងឡាយណាដែលទីតាំង ប្រភេទ ឬ ទំហំ មានលក្ខណៈនាំអោយប៉ះពាល់ដល់សុខមាលភាព ឬ ដល់សុវត្ថិភាពសាធារណៈ នាំអោយខូចខាត ឬ បណ្តាលអោយមានមហន្តរាយ ។

២៧.១ ទីដីគ្រោះថ្នាក់ (ទីដីដែលអាចមានគ្រោះថ្នាក់)

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះទីដីដែលអាចមានមហន្តរាយ តំបន់បាក់ស្រុតរលំ តំបន់ដីសើមដែលត្រូវការពារ តាមមាត់ច្រាំង ទន្លេ ព្រែក ស្ទឹង បឹងបួ ដែលពុំមានភាពរឹងមាំគ្រប់គ្រាន់ ហើយអាចបណ្តាលអោយមានគ្រោះថ្នាក់ ចំពោះសុវត្ថិភាពរបស់មនុស្ស និងសម្បត្តិទ្រព្យ លើកលែងតែភូមិដ្ឋានទាំងនោះបានអនុម័តតាមប្លង់គោល ។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះដីអាចលិចទឹក កាលណាសំណង់នោះស្ថិតតាមមាត់ច្រាំងទន្លេ លើព្រែក ស្ទឹង ឬ បឹង បណ្តាលអោយ

ថយចុះលទ្ធភាពរក្សាទឹកទុក ឬ លទ្ធភាពបង្ហូរទឹកពីទីដីនោះ និងទីដីជិតខាង និង ប៉ះពាល់ដល់គុណភាពទឹក ។

៧.២ ធាតុរំខានដោយសម្លេង

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ឬ អាចអនុញ្ញាតអោយតែក្នុងករណីក្រោមបញ្ញត្តិពិសេស បើសំណង់នោះអាចត្រូវទទួលរងធាតុរំខានដោយសំលេងខ្លាំងៗ ឬ បើសំណង់នោះអាចបង្កធាតុរំខានដោយសំលេងខ្លាំង ៗ ។

មាត្រា ២៨.–ការការពាររមណីយដ្ឋាន

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់នោះមានប្រភេទ ទំហំ ឬ ទីតាំងអាចបណ្តាលអោយអន្តរាយដល់ការអភិរក្ស ឬ អន្តរាយដល់ការលើកតំលៃនៃរមណីយដ្ឋានធម្មជាតិ ឬ ក្រុង ឬ កេរ្តិ៍ដំណែលប្រវត្តិសាស្រ្ត និង បូរាណវត្ថុ ឬ អាចអនុញ្ញាតអោយតែក្នុងករណីក្រោមបញ្ញត្តិពិសេស ។

មាត្រា២៩.–បណ្តាញផ្លូវពាក់ព័ន្ធ និង ចំណត

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះដីដែលពុំមានផ្លូវចេញចូល ដូចជា ផ្លូវសាធារណៈ ផ្លូវឯកជន ច្រកផ្លូវ ឬ ផ្លូវឆ្លងកាត់ ដែលទទឹងត្រូវសមាមាត្រស្របទៅនឹងទំហំ និងការប្រើប្រាស់នៃអគារ ។

រាល់ផ្លូវ ផ្លូវឆ្លងកាត់ ច្រកផ្លូវ សំរាប់ប្រើប្រាស់ចំពោះសំណង់មួយ ឬ ច្រើន ពុំអាចមានទទឹងតិចជាង ៣,៥០ម ដែលជាទំហំចាំបាច់សំរាប់អោយរថយន្តពន្លត់អគ្គីភ័យចូលបាន ។

ចំណតរថយន្តត្រូវមានគ្រប់គ្រាន់តាមសេចក្តីត្រូវការរបស់អគារ ហើយត្រូវស្ថិតនៅក្រៅពីផ្លូវសាធារណៈ ។ បទដ្ឋានចំណតរថយន្តត្រូវបានកំណត់ដោយ បណ្តាសាលាក្រុង និងសាលាខេត្ត ប៉ុន្តែពុំអាចតិចជាង៥ខ្ទង់ខាងក្រោមនេះ

–ចំពោះសណ្ឋាគារ

• ចំណតរថយន្តតូច ១កន្លែង សំរាប់ បន្ទប់ស្នាក់នៅ ...

• ចំណតរថយន្តធំ ១កន្លែង សំរាប់ បន្ទប់ស្នាក់នៅ ...

–ចំពោះការិយាល័យឯកជន និងរដ្ឋបាលសាធារណៈ ...

• ចំណតរថយន្ត ១កន្លែង សំរាប់ផ្ទៃក្រឡាកម្រាលសរុបទំហំ ២៥០ម៉ែត្រការេគុណ

_ចំពោះបណ្តាសកម្មភាព ឧស្សាហកម្ម សិប្បកម្ម និងឃ្លាំងស្តុកទំនិញ ចំនួនចំណតរថយន្តត្រូវមានគ្រប់គ្រាន់សំរាប់ការលើកដាក់ ផ្ទុក និងផ្ទេរទំនិញនៅក្រៅពីផ្លូវសាធារណៈ និងចំណតរថយន្តគ្រប់ប្រភេទនៅក្នុងបរិវេណដីឡូត៍ ។

មាត្រា៣០ ._ការបោះទីតាំងសំណង់ តាមដងផ្លូវសាធារណៈ

៣០.១ ការបោះទីតាំងសំណង់នៅតាមដងផ្លូវជាតិ និងផ្លូវទំនប់ព័ទ្ធជុំវិញទីក្រុង អភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងនានា និងរាជធានីភ្នំពេញ ត្រូវកំណត់ដោយមានការយល់ព្រម ពីគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ នូវដីចំណីសាធារណៈ និងផ្ចាតម្ចាត់នៃផ្លូវជាតិ ផ្លូវសំខាន់ៗ ដែលពាក់ព័ន្ធនឹងការរៀបចំទីក្រុង និងនគរូបនីយកម្ម ជាអាទិ៍ផ្លូវទំនប់ ។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ នៅក្នុងតំបន់ដែលបានរៀបរាប់ខាងលើ ។

៣០.២ ការបោះទីតាំងសំណង់នៅតាមដងផ្លូវសាធារណៈក្នុងក្រុង

សំណង់ទាំងឡាយ ត្រូវបោះទីតាំងលើផ្លូវតម្រង់ផ្លូវសាធារណៈ ឬ ឃ្លាតថយពីផ្លូវតម្រង់យ៉ាងតិច ៤ម៉ ។

នៅតាមច្រកផ្លូវ បណ្តាសំណង់អាចបោះទីតាំងលើផ្លូវតម្រង់ផ្លូវច្រក ។

អភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងនានា និងរាជធានីភ្នំពេញ កំណត់ផ្លូវតម្រង់នៃផ្លូវសាធារណៈ និងផ្ចាតម្ចាតលើប្លង់មួយហៅថា ប្លង់ផ្លូវតម្រង់។ ប្លង់ផ្លូវតម្រង់នេះ ត្រូវទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ ចំពោះក្រុងទាំងឡាយណាដែលមានប្រជាជនលើសពី ២០.០០០នាក់ ។ ប្លង់ទាំងនោះ ត្រូវផ្សព្វផ្សាយអោយសាធារណជនបានដឹង ។

មាត្រា៣១ ._ការផ្គត់ផ្គង់ទឹកស្អាត និងការបញ្ចេញចោលទឹកកខ្វក់

៣១.១ ការផ្គត់ផ្គង់ទឹកស្អាត ត្រូវធានាអោយបានចំពោះរាល់សំណង់ ដែលតំរូវអោយមានលិខិតអនុញ្ញាតសាងសង់ ។

ក្នុងករណីដែលបណ្តាញទឹកស្អាត ពុំផ្គត់ផ្គង់អោយទៅដល់ទីដីដែលនៅលើទីដីនេះ មានសំណង់មួយត្រូវបានគ្រោងទុកនោះ អ្នកស្នើសុំត្រូវបង្ហាញភស្តុតាងថា ខ្លួនអាចនឹងផ្គត់ផ្គង់ទឹកស្អាតក្នុងបរិមាណគ្រប់គ្រាន់ដល់អគាររបស់ខ្លួន និងបញ្ជាក់ថា តាមមធ្យោបាយអ្វី ទោះបីតាមការបន្តភ្ជាប់ទៅនឹងបណ្តាញទឹកស្អាតណាមួយដែលនៅជិត ឬ ជាអណ្តូងទឹកដែលមានស្រាប់នៅជិតនោះ ឬ ដែលត្រូវជីកថ្មីក្តី ។

អ្នកស្នើសុំត្រូវបញ្ជាក់អំពីលក្ខណៈបច្ចេកទេសរបស់អណ្តូង និងគុណភាពទឹក។ ក្នុងករណីការប្រើប្រាស់អណ្តូងសម្ភហភាព សំណុំលិខិតនៃលិខិតអនុញ្ញាតសាងសង់ត្រូវមានសេចក្តីយល់ព្រមអោយប្រើប្រាស់ទឹកជាលាយលក្ខអក្សរ ។

៣១.២ បណ្តាដីឡូត៍ ឬ សំណុំលំនៅដ្ឋាន ត្រូវតែមានការផ្គត់ផ្គង់ដោយបណ្តាញចែកចាយទឹកស្អាត និងមានប្រព័ន្ធលូទឹកស្អុយ ដែលនាំបង្ហូរចេញដល់ទីដៅតែម្តង ដោយគ្មានកន្លែងណាមួយអាចអោយទឹកស្អុយដក់នៅបាន ។

៣១.៣ ក្នុងករណីគ្មានប្រព័ន្ធលូទឹកស្អុយ ម្ចាស់សំណង់មានកាតព្វកិច្ចត្រូវគ្រោងសំអាតនិងបញ្ចេញទឹកដែលប្រើប្រាស់ហើយទៅទីធម្មជាតិ តាមរយៈអាងបង្គន់អនាម័យនិងបណ្តាញបំពង់មានប្រហោងរាយកប់ក្នុងដី ។

បណ្តាញនេះបែងចែកទឹកដែលចេញពីបង្គន់អនាម័យ នៅក្រោមដីធ្វើអោយជ្រាប និងជម្រះបាន ។ ម្ចាស់កម្មសិទ្ធិនៅក្នុងក្រុង ចាំបាច់ត្រូវធ្វើអាងបង្គន់អនាម័យ ហើយបន្តភ្ជាប់ទៅប្រព័ន្ធលូ ។ បទដ្ឋានអាងបង្គន់អនាម័យកំណត់ដូចតទៅ :

ទំហំប្រើប្រាស់នៃអាងបង្គន់អនាម័យ ដោយគិតពីបាតអាងឡើងមកដល់បំពង់បង្ហូរចេញ :

– ជាអប្បបរមា ៣ម៉ែត្រគ្រីគុណ សំរាប់លំនៅដ្ឋានមួយ ឬ ៣ម៉ែត្រគ្រីគុណក្នុងមួយជាន់នៃផ្ទះល្វែង ឬ នៃភូមិគ្រឹះ ឬ ៣ម៉ែត្រគ្រីគុណសំរាប់ផ្ទៃក្រឡាកំរាលសរុបទំហំ ៨០ម៉ែត្រទេ្វគុណ ។

ចំពោះសណ្ឋាគារ ២ម៉ែត្រគ្រីគុណ បូកបន្ថែម ០,៥ម៉ែត្រគ្រីគុណក្នុងមួយបន្ទប់ ;

– កំពស់អាងបង្គន់អនាម័យពុំអាចទាបជាង ១,៥០ម ។

– អាងបង្គន់អនាម័យត្រូវមានរន្ធបង្ហុយបន្តខ្ពស់ទៅលើ ។

- មិនត្រូវអោយទឹកភ្លៀងហូរចូលទៅក្នុងអាងបង្គន់អនាម័យជាដាច់ខាត ។

៣១.៤ សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ត្រូវមានគំនូរអាងបង្គន់អនាម័យ និង ប្រព័ន្ធបន្តភ្ជាប់ទៅលូបង្ហូរទឹកស្អុយ ។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើពុំបង្ហាញការធានាគ្រប់គ្រាន់អំពីអនាម័យ និងសុខមាលភាពចំពោះសំណង់ដែលបានគ្រោង និងបណ្តាសំណង់នៅជុំវិញដែលមានស្រាប់ ។

មាត្រា៣២ :- តំបន់មិនអាចសាងសង់បាន

ខេត្ត និងក្រុងនីមួយៗ ត្រូវកំណត់ជាបន្ទាន់នូវប្លង់តំបន់មិនអាចសាងសង់បាន ។

ប្លង់នេះ ត្រូវមានបញ្ចូលតំបន់ការពារធម្មជាតិ តំបន់កសិកម្ម តំបន់ព្រៃឈើ និងរ៉ែ ដែលជាគោលដៅប្រើប្រាស់ពុំអាចផ្លាស់ប្តូរបានដោយមូលហេតុផលប្រយោជន៍សេដ្ឋកិច្ចនិងបរិស្ថាន ។

ប្លង់នេះ ត្រូវមានបញ្ចូលរមណីយដ្ឋានធម្មជាតិ ដូចជា ឆ្នេរសមុទ្រ មាត់ទន្លេ ព្រែក ស្ទឹង បឹងបួ ដោយមូលហេតុផលប្រយោជន៍បេតិកភ័ណ្ឌ និងបរិស្ថាន ។

ប្លង់នេះត្រូវមានបញ្ចូលគ្រប់តំបន់អាចលិចទឹក ដែលត្រូវការពារដោយមូលហេតុជាផលប្រយោជន៍សំរាប់បង្ហូរទឹកភ្លៀងចេញ និងការប្រយុទ្ធប្រឆាំងនឹងទឹកជំនន់ ។

អាជ្ញាធរតាមមូលដ្ឋានត្រូវចាត់វិធានការសមស្រប ដើម្បីការពារ និងបង្កើនគុណសម្បត្តិតំបន់មិនអាចសាងសង់បានទាំងនោះ ។

រាល់លិខិតអនុញ្ញាតសាងសង់ មិនផ្តល់ជូនឡើយក្នុងតំបន់ទាំងនោះ ។

ក្នុងករណីមានការសាងសង់ដោយល្មើសច្បាប់ ក្នុងតំបន់ហាមឃាត់ទាំងនេះ អាជ្ញាធរដែនដីត្រូវបង្ខំអោយជនល្មើសរុះរើដោយខ្លួនឯង ហើយធ្វើអោយកន្លែងនោះមានសភាពដូចដើមវិញ ក្នុងរយៈកាលមួយកំណត់ ។

ក្នុងករណីមិនអនុវត្តតាមការកំណត់ អាជ្ញាធរដែនដីត្រូវធ្វើការផាកពិន័យ និងចាត់អោយរុះរើ និងធ្វើអោយកន្លែងនោះមានសភាពដូចដើមវិញ ដោយចាប់បង្ខំអោយអ្នកល្មើសច្បាប់ ត្រូវតែចេញសោហ៊ុយចំណាយទាំងអស់នោះ ឬ ក្នុងករណី

ចាំបាច់អាជ្ញាធរមូលដ្ឋានត្រូវប្តឹងទៅតុលាការ · ដើម្បីអោយចេញដីកាកិច្ចការប្រញាប់បញ្ជាអោយរុះរើ ។

ប្លង់នេះ ត្រូវទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ និងត្រូវផ្សព្វផ្សាយជាសាធារណៈដល់មន្ត្រីរាជការ ផ្នែកអាជ្ញាធរដែនដីមូលដ្ឋាន និងមន្ត្រីជំនាញទទួលខុសត្រូវលើ <តំបន់មិនអាចសាងសង់បាន> ដែលពុំបានចាត់វិធានការចាំបាច់ ដើម្បីអោយមានការគោរពតំបន់ទាំងនោះទេ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលតាមច្បាប់ជាធរមាន ។

មាត្រា៣៣ — ផលប៉ះពាល់ពីសំណង់ឧស្សាហកម្ម

សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ឧស្សាហកម្ម ត្រូវបញ្ជាក់អំពីការបំពុលបណ្តាលមកពីសកម្មភាពឧស្សាហកម្ម និងវិធីដែលបានគ្រោងទុក ដើម្បីលុបការបំពុលទាំងនោះ ។

គំរោងស្ថានីយ៍សំរាប់ធ្វើសំអាតតាមយថាប្រភេទ ត្រូវមានបញ្ចូលក្នុងសំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ។

រាល់កាកសំណល់ពីឧស្សាហកម្ម ត្រូវតែបានទទួលការសំអាតជាមុន ដើម្បីបង្ការកុំអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់ ឬ សុខភាពសាធារណៈ ។ ទឹកកខ្វក់សំណល់ឧស្សាហកម្ម ពុំត្រូវអោយលាយឡំជាមួយទឹកភ្លៀង និងជាមួយទឹកកខ្វក់ដទៃទៀត ហើយក៏ពុំត្រូវបង្ហូរចោលត្រង់ៗទៅក្នុងធម្មជាតិ ដោយពុំបានធ្វើការសំអាតជាមុនឡើយ ។

ចម្ងាយអប្បបរមាដែលត្រូវគោរពរវាងសំណង់ឧស្សាហកម្មមួយដែលមានធាតុកខ្វក់ និងលំនៅដ្ឋាននៅជិតបំផុត ត្រូវបានរដ្ឋអំណាចមូលដ្ឋានអនុវត្ត ស្របទៅតាមការណែនាំផ្ទាល់របស់រាជរដ្ឋាភិបាល ។

ចំពោះឃ្លាំងស្តុកឧសផ្ទៃ និងអាងប្រេងឥន្ធនៈទាំងឡាយ ត្រូវគោរពបទបញ្ញត្តិអន្តរជាតិ អនុម័តដោយរាជរដ្ឋាភិបាល ។

រាល់អំពើល្មើសនឹងបណ្តាបទបញ្ញត្តិខាងលើនេះ រដ្ឋអំណាចមូលដ្ឋានអាចបញ្ឈប់ការសកម្មភាពជាបន្ទាន់ ហើយត្រូវរាយការណ៍ជូនស្ថាប័នជំនាញ ។ រដ្ឋអំណាចត្រូវជូនដំណឹងតាមផ្លូវច្បាប់ដល់ម្ចាស់សំណង់ នូវបណ្តាបទបញ្ញត្តិដែលត្រូវគោរពតាម ។

ជំពូក ២

ការបោះទីតាំង និង ទំហំសំណង់

មាត្រា៣៤ .– ការបោះទីតាំងជៀបនឹងព្រំដីឡូត៍ជិតខាង

ជៀបនឹងព្រំដីឡូត៍ សំណង់ទាំងឡាយនឹងត្រូវសាងសង់ ឬមួយនៅជាប់នឹងព្រំ ឬមួយជាជញ្ជាំងអឡ្លសិទ្ធិ ឬមួយនៅចម្ងាយអប្បបរមា ២ម ពីព្រំ ។ ចន្លោះ ២ម នេះ ត្រូវទុកអោយនៅទំនេរពុំមានសំណង់អ្វីឡើយ ។

ហាមមិនអោយបោះទ្វារឬបង្អួច នៅលើជញ្ជាំងអឡ្លសិទ្ធិឬជញ្ជាំងជាប់ព្រំ ។

ចំពោះសំណង់ជាប់ព្រំ ឬ សំណង់ជាជញ្ជាំងអឡ្លសិទ្ធិ នឹងមានកំណត់ក្នុងសេចក្តីណែនាំអនុវត្តរបស់គណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ តាមសំណើរបស់ខេត្ត–ក្រុង ។

ត្រូវបានចាត់ទុកជាបន្ទប់រស់នៅ រាល់បន្ទប់ទាំងអស់លើកលែងតែផ្ទះបាយ បន្ទប់អនាម័យ បន្ទប់សេវាផ្សេងៗ និងចន្លោះដើរក្នុងអគារ ។ បទបញ្ញត្តិនេះត្រូវដាក់អោយអនុវត្តផងដែរចំពោះសណ្ឋាគារ ។

ក្នុងករណីនេះ រាល់បន្ទប់ដេក ក៏ដូចជារាល់បន្ទប់ទទួលភ្ញៀវ សុទ្ធតែត្រូវចាត់ទុកថាជាបន្ទប់រស់នៅ ។

បទបញ្ញត្តិនេះ ក៏ត្រូវដាក់អោយអនុវត្តផងដែរ ចំពោះកន្លែងធ្វើការ ។ ក្នុងករណីនេះ រាល់បន្ទប់ដែលមានមុខងារជាការិយាល័យ ឬ រោងជាងប្រើប្រាស់ជាទម្លាប់ ឬ ជាប្រចាំថ្ងៃ ត្រូវចាត់ទុកដូចជាបន្ទប់រស់នៅដែរ លើកលែងតែបន្ទប់មិនត្រូវការជាចាំបាច់នូវពន្លឺថ្ងៃ តាមមុខងារឬតាមប្រភេទរបស់វា ដូចជាបន្ទប់កុំព្យូទ័រ បន្ទប់ពិសោធន៍ ស្ទូឌីយោភាពយន្ត ។ល។

សាលាក្រុង ឬ សាលាខេត្ត អាចមានសិទ្ធិអោយបិទរាល់ច្រកប្រហោងណា ដែលពុំគោរពតាមចម្ងាយដូចបានរៀបរាប់ខាងលើនេះ ។

ចំពោះអគារមានពីមុនស្រាប់ ដែលពុំគោរពតាមបទបញ្ញត្តិដូចបានរៀបរាប់ខាងលើនេះទេ សាលាក្រុង ឬ សាលាខេត្ត អាចទាមទារអោយបង្កើតរបាំងការពារ កុំអោយមានគំហើញត្រង់ទៅលើដីឡូត៍អ្នកជិតខាង ។

របាំងការពារទាំងនេះ អាចជាជញ្ជាំងមានប្រឡោះខ្យល់ ផ្ទាំងឈើ ឬអ្វីៗផ្សេងទៀត ដែលពុំរាំងខ្ទប់ដំណើរខ្យល់បក់ចេញចូលក្នុងបន្ទប់រស់នៅ ។

ចាត់ទុកជាបង្អួច រាល់ប្រហោងនានាដែលបណ្តាលអោយមានគំហើញត្រង់ឆ្ពោះទៅលើអ្នកជិតខាង ។ ក្នុងករណីណាក៏ដោយ គេអាចប្រើប្រាស់បានរាល់របាំងធ្វើពីឈើ ឬ បេតុង ស្លាបព្រិលចាក់ប៊ើក ធ្វើពីឈើ ឬ កញ្ចក់ស្រអាប់ និងស្លាបព្រិលនៅនឹងថ្កល់ ។

មាត្រា៣៥ ._ផ្ទៃបាត

ចំពោះផ្ទះល្វែង និងអគារលំនៅដ្ឋានសមូហភាព ផ្ទៃបាតសំណង់ធៀបទៅនឹងផ្ទៃក្រឡារបស់ដីឡូត៍ ពុំអាចលើសពី ៧៥% ឡើយ ។

ចំពោះផ្ទះជាលំនៅដ្ឋាន ផ្ទៃបាតសំណង់នោះពុំអាចលើសពី ៥០% នៃផ្ទៃក្រឡាដីឡូត៍ឡើយ ។

ផ្ទៃក្រឡាដីឡូត៍ ដែលនៅសល់ពីការសាងសង់ ត្រូវរៀបចំជាសួនដោយដីជ្រាបទឹក អោយបានយ៉ាងតិចពាក់កណ្តាលផ្ទៃក្រឡានេះ ។

ចំពោះអគារដែលមានយ៉ាងតិច ១៥លំនៅ សណ្ឋាគារ អគារការិយាល័យ និងអគារឧស្សាហកម្ម ផ្ទៃបាតសំណង់ពុំអាចលើសពី ៥០% នៃផ្ទៃក្រឡាដីឡូត៍ឡើយ ។

ផ្ទៃក្រឡាដែលនៅសល់ពីសំណង់ នឹងត្រូវរៀបចំជាសួនដោយដីជ្រាបទឹក អោយបានយ៉ាងតិចពាក់កណ្តាលផ្ទៃក្រឡានេះ ។

សាលាក្រុង និង សាលាខេត្ត ត្រូវកំណត់តំបន់រៀបចំក្រុង ដែលត្រូវយកបទបញ្ជាខាងលើនេះមកអនុវត្ត ហើយនឹងត្រូវកំណត់បទបញ្ញត្តិពិសេស ចំពោះស្ថានភាពជាក់ស្តែង ។

មាត្រា៣៦ ._ប្លង់កំពស់

សាលាក្រុង និង សាលាខេត្តនីមួយៗ នឹងលើកគំរោងប្លង់កំពស់ក្នុងរយៈពេលមួយឆ្នាំ ក្រោយពីបានការអនុម័តលើអនុក្រឹត្យនេះរួច ដោយកំណត់អោយតំបន់នីមួយៗនៃក្រុងកំពស់អតិបរមានៃសំណង់ ។

ប្លង់កំពស់នេះត្រូវគិតដល់ :

• កំពស់មធ្យម បច្ចុប្បន្នតាមសង្កាត់នីមួយៗ ។

• លក្ខណៈសំខាន់នៃតំបន់ (ពាណិជ្ជកម្ម លំនៅដ្ឋាន ឧស្សាហកម្មនៅកណ្តាលក្រុង ឬ ជាយក្រុង ដីចាក់បំពេញ ឬ អត់ ការប្រើប្រាស់ទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធ ។ល។) ។

• ប្រភេទនៃសំណង់ (ផ្ទះល្វែង ភូមិគ្រឹះ គ្រឹះស្ថាន ឃ្លាំងស្តុកទំនិញ និង អគារឧស្សាហកម្ម... ។ល។) ។

ប្លង់កំពស់នេះ ត្រូវបានទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ហើយផ្សព្វផ្សាយជាសាធារណៈ ។

មាត្រា៣៧ .– ការការពារប្រាង្គប្រាសាទ និងទេសភាព

សាលាក្រុង និងសាលាខេត្តនីមួយៗ អាចកំណត់កំពស់អតិបរមាទាបជាងកំពស់អតិបរមាក្នុង <ប្លង់កំពស់> ដើម្បីការពារបូជនីយស្ថានប្រវត្តិសាស្ត្រមណីយដ្ឋានធម្មជាតិ ក៏ដូចជាកន្លែងនៅជិតៗប្រាង្គប្រាសាទប្រវត្តិសាស្ត្រ ឬ ដើម្បីរក្សាទុកនូវទស្សនវិស័យនៃប្រាង្គប្រាសាទ និងទស្សនវិស័យដ៏ស្អិតស្អែ ។

ការបន្ថយកំពស់នេះ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ និងប្រាប់ដល់អ្នកសុំលិខិតអនុញ្ញាតសាងសង់មុនពេលដាក់សំណុំលិខិតស្នើសុំ ។

ជំពូក ៣

និក្ខេបនៃសំណង់

មាត្រា៣៨ .– លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់ដែលគ្រោងនោះមានទីតាំងស្ថាបត្យកម្ម (Architecture) ទំហំ ឬ ទិដ្ឋភាពក្រៅអាចនាំអោយប៉ះពាល់ដល់លក្ខណៈ ឬ ផលប្រយោជន៍របស់ទីតាំងនៅជុំវិញ ប៉ះពាល់ដល់ទេសភាពធម្មជាតិ ឬ ទីក្រុង ភាពស្ងប់របស់ទីសក្ការៈបូជា រមណីយដ្ឋានប្រវត្តិសាស្ត្រ ឬ បុរាណសាស្ត្រ រាជវាំង និង រាជប្រាង្គប្រាសាទ ។

មាត្រា៣៩ .– លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើលក្ខណៈសំណង់នោះមិនធានាសុខមាលភាព បន្ទប់ស្នាក់នៅ ឬ បន្ទប់ធ្វើការនីមួយៗ ត្រូវអោយមានខ្យល់ចេញ–ចូល ហើយត្រូវមានបង្អួចមួយយ៉ាងតិច ។

ផ្ទៃក្រឡាបញ្ចូលពន្លឺថ្ងៃសំរាប់បន្ទប់នីមួយៗ ត្រូវមានយ៉ាងតិច ១,៥០ម^2 ។

មាត្រា៤០ ._បណ្តាសំណង់ឧស្សាហកម្ម អាចតម្រូវអោយគោរពលក្ខខ័ណ្ឌពិសេសចំពោះការរៀបចំ ឬ ការបោះទីតាំងដើម្បីធានាការបញ្ចូលអោយបានល្អទៅក្នុងទេសភាព និងរមណីយដ្ឋានធម្មជាតិ ឬ ទីក្រុង ។

មាត្រា៤១._នៅតាមឆ្នេរសមុទ្រ តាមមាត់បឹង ស្ទឹង និងទន្លេ លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់នោះធ្វើអោយខូចនូវសោភណភាពរបស់ទេសភាព និងរមណីយដ្ឋាន ដោយសារទិដ្ឋភាព ឬ កំពស់របស់សំណង់ បើមើលពីមាត់ឆ្នេរ ពីមាត់ច្រាំង ពីសមុទ្រ ស្ទឹង ទន្លេ ឬ បឹងបួ និងប៉ះពាល់ដល់គុណភាពទឹក ។

ជំពូក ៤

សន្ទភាព (ដង់ស៊ីតេ) : កំរិតអតិបរមាច្បាប់នៃសន្ទស្សន៍ប្រើប្រាស់

មាត្រា៤២._ការស្ថាបនាសំណង់មួយមានសន្ទភាព លើសពីកំរិតអតិបរមាស្របច្បាប់ តម្រូវអោយអ្នកទទួលលិខិតអនុញ្ញាតសាងសង់ បង់ប្រាក់ស្មើនឹងតំលៃដីដែលចាំបាច់ ដើម្បីអោយ <សន្ទស្សន៍ប្រើប្រាស់> សំណង់មិនលើសពីកំរិតនេះ ។

មាត្រា៤៣._<សន្ទស្សន៍ប្រើប្រាស់> ត្រូវបានកំណត់ដោយអនុបាតរវាងផ្ទៃក្រឡាកម្រាលសរុបជាផ្ទះ (Hors oeuvre nette) នៃសំណង់នោះ និងផ្ទៃក្រឡាដីដែលសំណង់នោះនឹងត្រូវ ឬ បានតាំងនៅលើ ។ កាលណាសំណង់ថ្មីមួយ បានត្រូវសាងសង់លើដីមួយកន្លែងដែលមានអគារចាស់មួយ ឬ ច្រើន ហើយគ្មានគំរោងរុះរើពេលនោះទេ សន្ទភាពត្រូវគណនាដោយថែមផ្ទៃក្រឡាកម្រាលនៃសំណង់ចាស់ ទៅលើផ្ទៃក្រឡាកំរាលនៃសំណង់ថ្មី ។

មាត្រា៤៤._ កំរិតអតិបរមាស្របច្បាប់នៃសន្ទស្សន៍ប្រើប្រាស់ ត្រូវកំណត់ដល់ (១) សំរាប់ទូទាំងដែនដីក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៤៥._ការផ្តល់លិខិតអនុញ្ញាតសាងសង់ នាំមកអោយអ្នកបានទទួលលិខិតអនុញ្ញាតសាងសង់ នូវកាតព្វកិច្ចអោយបង់ប្រាក់នោះ ។ ការបង់ប្រាក់ត្រូវធ្វើជាបីភាគស្មើគ្នា ភាគទី១ នៅពេលបានទទួលលិខិតអនុញ្ញាតសាងសង់ ភាគទី២ នៅពេលបើកការដ្ឋាន ភាគទី៣ នៅពេលបញ្ចប់សំណង់ ។

មាត្រា៤៦._តំលៃដីសំរាប់ការគណនាចំនួនទឹកប្រាក់ដែលត្រូវបង់ ត្រូវបានកំណត់ដោយក្រសួងហិរញ្ញវត្ថុ ។

មាត្រា៤៧.– កិរិតស្របច្បាប់នៃ <សន្ទស្សន៍ប្រើប្រាស់> ពុំត្រូវអនុវត្តឡើយ ចំពោះសំណង់ដែលពុំតម្រូវអោយមានលិខិតអនុញ្ញាតសាងសង់ ចំពោះគ្រឹះស្ថានសាធារណៈ និងចំពោះអគាររដ្ឋបាលសាធារណៈសំរាប់បំរើផ្ទាល់មុខ ជាកន្លែងធ្វើការសំរាប់ស្ថាប័នសាធារណៈ ។

នាយករដ្ឋមន្ត្រី អាចសំរេចលើកលែងការអនុវត្តន៍កិរិតស្របច្បាប់នៃ <សន្ទស្សន៍ប្រើប្រាស់> ចំពោះបណ្ដាតំបន់រៀបចំពិសេស បន្ទាប់ពីបានយោបល់ពីគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ ។

<វាសនដ្ឋានសង្គម> ទាំងឡាយអាចទទួលនូវការលើកលែងមិនអោយបង់ពន្ធអាករ តាមសេចក្ដីសំរេចរបស់អភិបាលខេត្ត–ក្រុង បន្ទាប់ពីបានទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ។

ជំពូក ៥

បទបញ្ជាពិសេស សំរាប់អនុវត្តលើភាគខ្លះ នៃដែនដី

មាត្រា៤៨.– ជាការបន្ថែមដល់បទបញ្ជាទូទៅនៃការប្រើប្រាស់ដី–ធ្លី ការណែនាំមួយចំនួនសំរាប់ការរៀបចំតំបន់ និងបទបញ្ជានគរូបនីយកម្មពិសេសមួយចំនួន អាចត្រូវតាក់តែងឡើងដោយអនុក្រឹត្យដែលអាចមានរហូតដល់ការហាមមិនអោយសាងសង់នៅក្នុង <តំបន់ចាប់អារម្មណ៍> ដូចជា ឆ្នេរសមុទ្រ មាត់ច្រាំងទន្លេ និងបឹងធំៗ ។ រាល់ឯកសារ <នគរូបនីយកម្មមូលដ្ឋាន> និងប្លង់ខេត្តនៃតំបន់ហាមមិនអោយមានសំណង់ ដែលចែងក្នុងមាត្រា ៣២ វគ្គទី ២ នៃអនុក្រឹត្យនេះត្រូវទុកជាការណែនាំទាំងនេះ និងការហាមជាយថាហេតុមិនអោយសាងសង់ ។

មាត្រា៤៩ .–បទបញ្ញត្តិទាំងឡាយមានពីមុនដែលផ្ទុយនឹងអនុក្រឹត្យនេះ ចាត់ទុកជានិរាករណ៍ ។

មាត្រា៥០.–ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង អភិបាលខេត្ត សមាជិកគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ និងក្រសួងស្ថាប័ន ពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមតួនាទីចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

អនុក្រឹត្យ លេខ ៨៧ អនក្រ.បក

ស្តីពី

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិ

រៀបចំទឹកដី នគរូបនីយកម្ម និងសំណង់

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០៤ នស ៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់
- តាមសំណើរបស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌និងវិចិត្រសិល្បៈ រៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩៧

សម្រេច

មាត្រា ១ : ត្រូវបានបង្កើតគណៈកម្មាធិការជាតិមួយឈ្មោះថា «គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ » (CNATUC) ។ សមាសភាពនៃគណៈកម្មាធិការជាតិ ត្រូវតែងតាំងដោយសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ។

គណៈកម្មាធិការជាតិនេះ រួមមានសមាសភាពដូចតទៅ :

_ទេសរដ្ឋមន្ត្រីទទួលវប្បធម៌ វិចិត្រសិល្បៈរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់		ប្រធាន
_សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	ឬ តំណាង	អនុប្រធាន
_រដ្ឋមន្ត្រីសាធារណការនិងដឹកជញ្ជូន	ឬ តំណាង	អនុប្រធាន
_សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	ឬតំណាង	សមាជិក
_សហរដ្ឋមន្ត្រីក្រសួងការពារជាតិ	ឬ តំណាង	សមាជិក
_រដ្ឋមន្ត្រីក្រសួងបរិស្ថាន	ឬ តំណាង	សមាជិក
_រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	ឬ តំណាង	សមាជិក
_រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ	ឬ តំណាង	សមាជិក
_រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ	ឬ តំណាង	សមាជិក

ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ត្រូវអញ្ជើញរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធចូលរួមបំពេញបន្ថែម ក្នុងគណៈកម្មាធិការជាតិតាមករណីនីមួយៗ ។

តំណាងរដ្ឋមន្ត្រី ត្រូវមានថ្នាក់យ៉ាងតិចស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ . _ដោយឈរលើមូលដ្ឋាននៃច្បាប់ និងបទដ្ឋានជាធរមាន និងក្នុងក្របខ័ណ្ឌនៃនគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចដូចតទៅ :

១_ណែនាំ និងកំណត់ទិសដៅក្នុងការរៀបចំប្លង់គោលរបស់រាជធានីភ្នំពេញ និងខេត្ត_ក្រុង ដើម្បីការពារធនធានធម្មជាតិនានា ដី ទឹក ខ្យល់ ព្រៃឈើ ទេសភាព និងសម្បត្តិវប្បធម៌ ឬ បេតិកភណ្ឌជាតិ ។

២_ចងក្រងគោលនយោបាយសំរាប់លើកកំពស់សម្បជញ្ញៈរបស់ប្រជារាស្ត្រអោយរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យផ្សេងៗ ដូចជាសង្គមកិច្ច សេដ្ឋកិច្ច វប្បធម៌ ទាំងនៅជនបទ ទាំងនៅទីក្រុង ។

៣_ណែនាំធ្វើការសិក្សា ដើម្បីបង្កើតប្លង់ តាមភាគផ្នែកៗ ក្នុងទីរួមខេត្ត និងក្រុងនានា ដោយសំរបសំរួលទៅតាមលក្ខខ័ណ្ឌនៃទីកន្លែង ។

៤_តាមដាន និងពិនិត្យមើលសំណង់គ្រប់ប្រភេទ ដើម្បីអោយសមស្របជាមួយបរិស្ថានធម្មជាតិ ។

៥_គ្រោងតំបន់រក្សាទុក ដើម្បីបំរើអោយសេចក្តីត្រូវការ នាពេលអនាគតសំរាប់អភិវឌ្ឍន៍គ្រប់សកម្មភាពដោយអនុលោមទៅតាមប្លង់គោល ។

៦_កំណត់អោយការពារ និងថែរក្សាទុកអោយទំនេរ តំបន់ជុំវិញ មាត់ឆ្នេរសមុទ្រ មាត់ទន្លេ មាត់ជ្រោះ មាត់អូរ និងមាត់ព្រែក ព្រមទាំងបឹង ត្រពាំង ទំនប់ អនុលោមទៅតាមការកំណត់របស់ប្លង់គោល ដើម្បីទុកអោយប្រជាពលរដ្ឋប្រើប្រាស់ទឹកដោយសេរី និងសំរាប់ការធ្វើដំណើរ ។

៧_កំណត់អោយការពាររមណីយដ្ឋានធម្មជាតិ តំបន់ព្រៃឈើ និងរមណីយដ្ឋាននានាដែលត្រូវបានកំណត់ដោយច្បាប់បេតិកភ័ណ្ឌវប្បធម៌ ។

៨_កំណត់ព្រំ តំបន់លំនៅដ្ឋាន សំរាប់សកម្មភាព សេដ្ឋកិច្ច វប្បធម៌ រដ្ឋបាល ទៅតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ដោយរៀបចំបណ្តាញចែកចាយទឹក និងអគ្គិសនី ផ្លូវគមនាគមន៍ ការដឹកជញ្ជូន ព្រមជាមួយការការពារបរិស្ថាន ដោយបំបាត់ក្លិនអាក្រក់ ភាពកខ្វក់ និងការរំខាន បណ្តាលមកពីសូរសំលេងជាដើម។

៩_កំណត់តំបន់ហាមឃាត់ការបោះទីតាំង និងសំណង់នៅទីកន្លែងសាធារណៈ និងទីកន្លែងជាផលប្រយោជន៍ទូទៅ ដូចជាសាលារៀន ទីលានកីឡា សួនច្បារ ផ្លូវថ្នល់សាធារណៈ ដីចំណីសងខាងផ្លូវសាធារណៈ បរិវេណវត្តអារាម គ្រឹះស្ថានសុខាភិបាល ដីចំណីសងខាងផ្លូវដែក បណ្តាញលូទឹក... ។ល។

១០_សហការជាមួយបណ្តាក្រសួង មន្ទីរ និងអង្គភាពពាក់ព័ន្ធ ដើម្បីតាក់តែងគំរោងច្បាប់ និងអត្ថបទច្បាប់ទាក់ទងនិងក្រុងភ្នំពេញ ជនបទ និងក្រុងនានា ហើយដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងដាក់ស្នើសុំការអនុម័តពីសភាជាតិ ។

១១_ចាត់ចែងការអប់រំប្រជាពលរដ្ឋ អោយម្នាក់ៗភ្ញាក់រលឹក ចំពោះករណីយកិច្ចរបស់ខ្លួន និងចូលរួមចំណែកក្នុងការការពារបរិស្ថាន និងការលំអទេសភាពនៅរាជធានី ក៏ដូចជានៅតាមទីប្រជុំជនក្រុង និងទីប្រជុំជនជនបទ ។

១២_សំរបសំរួលការងារបច្ចេកទេស និងកិច្ចការផ្សេងៗ ទៀតដល់គណៈកម្មាធិការ និងបណ្តាអនុគណៈកម្មាធិការខេត្ត–ក្រុង តាមច្បាប់ និងបទបញ្ញត្តិជាធរមាន តាមលទ្ធភាព និងតំរូវការជាក់ស្តែង ។

មាត្រា ៣ .– គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ មានអគ្គលេខាធិការដ្ឋានប្រតិបត្តិមួយជាជំនួយការ និងគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ រាជធានីភ្នំពេញ និងអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ខេត្ត–ក្រុង ជាសេនាធិការ ។

គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ មានការិយាល័យកិច្ចការនគរូបនីយកម្មក្រុង ជាសេនាធិការ ។

អនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ នៅតាមបណ្តាខេត្ត–ក្រុង មានការិយាល័យកិច្ចការនគរូបនីយកម្ម ខេត្ត–ក្រុង ជាសេនាធិការ ។

ការិយាល័យកិច្ចការនគរូបនីយកម្ម ស្ថិតនៅក្រោមការគ្រប់គ្រងផ្នែករដ្ឋបាលរបស់សាលាខេត្ត–ក្រុង និងរាជធានីភ្នំពេញ និងផ្នែកបច្ចេកទេស ពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ។

គណៈកម្មាធិការ និងអនុគណៈកម្មាធិការខេត្ត–ក្រុងនេះ ត្រូវបានទទួលការណែនាំបច្ចេកទេសពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងទទួលការគ្រប់គ្រងដឹកនាំផ្ទាល់ ផ្នែករដ្ឋបាលពីសាលាខេត្ត–ក្រុង ។

មាត្រា ៤ .– គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ លើកសំណើតែងតាំងអ្នកជំនួយការមួយរូបជាអគ្គលេខាធិការ ។

_អគ្គលេខាធិការ ត្រូវបានប្រគល់សិទ្ធពីប្រធានគណៈកម្មាធិការជាតិ រៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ ដើម្បីប្រតិបត្តិរាល់បេសកកម្មដែលប្រធានប្រគល់អោយទទួលបន្ទុកតាមស្មារតីនៃអនុក្រឹត្យនេះ ហើយអាចតំណាងប្រធានក្នុងក្របខ័ណ្ឌនេះ ។

–អគ្គលេខាធិការរៀបចំ និងចាត់ចែងសម័យប្រជុំរបស់គណៈកម្មាធិការរៀបចំ ទឹកដីនគរូបនីយកម្ម និងសំណង់ ដោយទំនាក់ទំនងជាមួយបណ្តាសមាជិក នៃគណៈកម្មាធិការជាតិ និងដោយមានការព្រមព្រៀងជាមួយប្រធានជាមុន ។

មាត្រា ៥ .–អគ្គលេខាធិការ មានភារកិច្ចដឹកនាំ លេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ និងរៀបចំជាមុខជំនាញផ្សេងៗ ដូចជា :

–គ្រប់គ្រងកិច្ចការបច្ចេកទេស និងឯកសារ នគរូបនីយកម្ម

–គ្រប់គ្រង និងលើកកម្មវិធីសកម្មភាព ផ្នែកនីតិកម្ម និងនីតិវិធី

–អធិការកិច្ច

សមាជិកលេខាធិការដ្ឋានអចិន្ត្រៃយ៍ ត្រូវបានទទួលភារកិច្ចពីអគ្គលេខាធិការក្រោយពីមានការយល់ព្រមពីប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ។

មាត្រា ៦ .–គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ មានទីស្នាក់ការនៅទីស្តីការគណៈរដ្ឋមន្ត្រី ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

រាល់មន្ត្រីរាជការបំរើនៅគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ត្រូវតែងតាំងដោយដាក់អោយនៅក្រោមដំណែងពីក្រសួង មន្ទីរពាក់ព័ន្ធ ។ ក្នុងករណីចាំបាច់ទៅតាមតំរូវការការជ្រើសរើសចូលត្រូវអនុវត្តតាមសហលក្ខន្តិកៈមន្ត្រី រាជការស៊ីវិល តាមរយៈស្ថាប័នអចិន្ត្រៃយ៍របស់រាជរដ្ឋាភិបាល ។

រាល់ចំណាយសំរាប់ដំណើរការ នៃគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ រួមមានបៀវត្សរបស់បុគ្គលិក ទីស្នាក់ការសំភារៈ និង មធ្យោបាយដឹកជញ្ជូន ត្រូវបានចែងក្នុងថវិកាជាតិប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រីតាមសំណើថវិកា របស់គណៈកម្មាធិការជាតិ រៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ។

គណៈកម្មាធិការជាតិ រៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ មាន សិទ្ធិធ្វើសហប្រតិបត្តិការជាមួយស្ថាប័នជាតិ អន្តរជាតិ អង្គការ [illegible] អង្គការមូលនិធិ

តំបន់ ដើម្បីសុំជំនួយជាថវិកាក្នុងការធ្វើអោយសុក្រឹត្យ នូវរាល់គំរោង និងទិសដៅ ដូចបានរៀបរាប់ខាងលើ ។

មាត្រា ៧ .–គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ នៃក្រុងភ្នំពេញមាន ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន ។

–ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ប្រធាន
–ប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ អនុប្រធាន
–អភិបាលរងរាជធានីភ្នំពេញ សមាជិក
–ប្រធានមន្ទីរស៊ីវិលយោធីក្រុងភ្នំពេញ សមាជិក
–ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនក្រុងភ្នំពេញ សមាជិក
–ប្រធានមន្ទីររៀបចំក្រុង និងសំណង់ក្រុងភ្នំពេញ សមាជិក
–ប្រធានមន្ទីរនគរបាលក្រុងភ្នំពេញ សមាជិក
–ប្រធានមន្ទីរបរិស្ថានក្រុងភ្នំពេញ សមាជិក
–នាយកការិយាល័យកិច្ចការនគរូបនីយកម្ម សមាជិក

នាយកមន្ទីរដទៃទៀត និងត្រូវចូលរួមក្នុងសម័យប្រជុំ តាមសេចក្ដីត្រូវការ របស់គណៈកម្មាធិការ ។

មាត្រា ៨ .–អនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ខេត្ត–ក្រុង ដទៃទៀត មានអភិបាលខេត្ត–ក្រុងជាប្រធាន ។

អនុគណៈកម្មាធិការនេះរួមមាន បណ្ដាអង្គភាពបច្ចេកទេស ដែលត្រូវបាត់តាំងដោយអភិបាលខេត្ត–ក្រុង បន្ទាប់ពីបានទទួលការយល់ព្រម ពីប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ។

មាត្រា ៩ .–ក្នុងករណីមានសំណើពីអភិបាលខេត្ត–ក្រុង គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ រាជធានីភ្នំពេញ និង បណ្ដាអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត–ក្រុង អាចចូលរួមចំណែកអនុវត្តភារកិច្ចដែលបានកំណត់ក្នុងមាត្រា ១៨ នៃច្បាប់រៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ។

មាត្រា១០ .–ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ និងត្រូវកំណត់ដោយអនុក្រឹត្យ ហើយបណ្ដាអនុគណៈកម្មាធិការរៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ខេត្ត–ក្រុងនឹងត្រូវកំណត់ដោយប្រកាស របស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់។

មាត្រា១១ .–បទបញ្ញត្តិទាំងឡាយដែលកំពុងប្រើប្រាស់បច្ចុប្បន្ន ហើយផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា១២ .–ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ អភិបាលខេត្ត–ក្រុង សមាជិកគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមតួនាទីរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

*****

អនុក្រឹត្យ លេខ ២៥១ អនក្រ.តត

ស្ដីពីការតែងតាំង មន្ត្រីរាជការ

* * * * *

រាជរដ្ឋាភិបាលកម្ពុជា

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧-៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-តាមសំណើរបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

មាត្រា ១ -តែងតាំងលោក **គង់ ហ៊ុន ធារិទ្ធ** ជាទីប្រឹក្សាឯកឧត្តម **ឧកញ៉ា តាន់** សហរដ្ឋមន្ត្រីស្តីទី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២ -សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងលោក **គង់ ហ៊ុន ធារិទ្ធ** ត្រូវអនុវត្តអនុក្រឹត្យនេះដែលចូលជាធរមានចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត ហ៊ុន សែន

* * * *

អនុក្រឹត្យលេខ ២៥២ អនក្រ.តត
ស្តីពីការតែងតាំង មន្ត្រីរាជការ រាជរដ្ឋាភិបាលកម្ពុជា

* * * * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រតក/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- ពិនិត្យសំណូមពរការងារ និងសមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

មាត្រា ១ .- ត្រូវតែងតាំង

លោក អ៊ុក រ៉ាស៊ី ជាជំនួយការទទួលបន្ទុកកិច្ចការអប់រំរបស់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ ដោយមានឋានៈស្មើនឹង ប្រធាននាយកដ្ឋាន ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត ហ៊ុន សែន

អនុក្រឹត្យ លេខ ២៥៣ អនក្រ.គត
ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- តាមសំណើរបស់រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនអង្គភាព ០៣ នៃសមាគមសហប្រតិបត្តិការ ជប៉ុន ដែលបានចូលរួមក្នុងការកសាងមជ្ឈមណ្ឌលវិជ្ជាជីវៈភ្នំពេញ រាប់បំរើអោយជនពិការ និងកុមារកំព្រាចំណាយអស់ទឹកប្រាក់ចំនួន ៣២៨.២០៩,៦០ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ ÷

ក_មេដាយថ្នាក់ស្ថាបនាជាតិ :

១_អង្គភាព OHSHIMA MEGUMI NO SONO KAZOKUKAI

២_អង្គភាព MEGUMI GROUP

ខ_មេដាយ សេរីវឌ្ឍ ស្ថាបនាជាតិ :

១_អង្គភាព (SOCIAL WELFARE CORP) MUSASHINOKAI OHSHIMA MEGUMI NO SONO

មាត្រា ២ ._សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត ហ៊ុន សែន

****

អនុក្រឹត្យ លេខ ២៥៤ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

*****

រាជរដ្ឋាភិបាលកម្ពុជា

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

_បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យលេខ ជស/រតក/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

_តាមសំណើរបស់អភិបាលខេត្តកំពង់ឆ្នាំង

សំរេច

មាត្រា ១ _ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិ ជូនលោក **ស្វាយ សុគុណា** ហៅ **ប៉ាច** និងក្រុមគ្រួសាររស់នៅប្រទេសស្វីស ដែលបានធ្វើអំណោយជាថវិកា ចំនួន ១៦.៧០០ដុល្លារសហរដ្ឋអាមេរិក សំរាប់កសាងអគារសិក្សា ១ខ្នង នៅក្នុងភូមិមេលំ ឃុំមេលំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។

មាត្រា ២ _សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

* * * *

អនុក្រឹត្យ លេខ ២៥៥ អនក្រ.តត

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

រាជរដ្ឋាភិបាលកម្ពុជា

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រតក/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រតក/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួល សមាសភាពរាជរដ្ឋាភិបាល

-តាមសំណើរបស់ឯកឧត្តម **ខាម យឿប**

សំរេច

មាត្រា ១ .-ត្រូវបានប្រគល់ មេដាយ ប្រាក់ ស្ថាបនាជាតិជូនលោកស្រី **ខែម សុឃុន** ពាណិជ្ជករ នៅផ្សារអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង ដែលបានខិតខំខ្នះខ្នែងអស់ពីកំលាំងកាយចិត្ត និងបរិច្ចាគថវិកាផ្ទាល់ខ្លួន ជាង១៥លានរៀល ដើម្បីទ្រទ្រង់ទំនប់សម្តេច **ហ៊ុន សែន** សំរាប់ការពារទឹកជំនន់ នារដូវវស្សាកន្លងទៅ ។

មាត្រា ២ .-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត **ហ៊ុន សែន**

* * * *

អនុក្រឹត្យ លេខ ២៥៦ អនក្រ.តត

ស្តីពីការតែងតាំង មន្ត្រីរាជការ

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រតក/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- យោងតាមសំណូមពររបស់ក្រសួងពត៌មាន

សំរេច

មាត្រា ១ .- តែងតាំងលោក **សម សារិន** ជាប្រធាននាយកដ្ឋាន ទូរទស្សន៍នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ក្រសួងពត៌មាន ។

មាត្រា ២ .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងដែលពាក់ព័ន្ធនិងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

អនុក្រឹត្យ លេខ ២៥៧ អនក្រ.តត
ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រតក/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រតក/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល
- តាមសំណើរបស់អភិបាលខេត្តព្រៃវែង

សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយ មាស ស្ថាបនាជាតិជូនចំពោះសប្បុរសជន ០២រូប ដែលបានឧបត្ថម្ភថវិកាសំរាប់ជួយកសាងវិស័យសុខាភិបាល នៅខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោមនេះ ÷

១- លោក **Dr. CLAUS WINTER** អនុប្រធានសមាគមគ្រូពេទ្យធ្មេញអាល្លឺម៉ង់ ឧបត្ថម្ភថវិកា ១៤១.៦៦៣$US

២- លោក **Dr. CERTRUD SCHMIDT EHRY** ទីប្រឹក្សាផ្នែកសុខាភិបាលនៃអង្គការ GTZ អាល្លឺម៉ង់ ឧបត្ថម្ភថវិកា ៨៤.០០០$US

មាត្រា ២ .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខាៈ

អ៊ុង ហួត ហ៊ុន សែន

អនុក្រឹត្យ លេខ ២៥៨ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រតក/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រតក/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួល សមាសភាពរាជរដ្ឋាភិបាល
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២

សំរេច

មាត្រា ១ - ត្រូវបានប្រគល់ មេដាយ ស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនសប្បុរសជនដែលបានឧបត្ថម្ភថវិកាតាមរយៈសម្តេចនាយករដ្ឋមន្ត្រីទី២ ដើម្បីកសាងសាលាបាលី និងសួនច្បារនៅក្នុងវត្តវិហារសំណរ ដូចមានរាយនាមខាងក្រោមនេះ ÷

ក-មេដាយ មាស ស្ថាបនាជាតិ :

- លោកឧកញ៉ា **សំ អាង** និងលោកស្រី **ឈុន លាង** ប្រធានក្រុមហ៊ុនវឌ្ឍនៈ ថវិកា ១៥.០០០$US

ខ-មេដាយ សំរិទ្ធ ស្ថាបនាជាតិ :

- លោក អ៊ុត ឈួន ប្រធាននាយកដ្ឋានក្បៀតក្រសាស្ត្រ ថវិកា ២.០០០$US

មាត្រា ២ .-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងនាយកខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រីទី២ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

* * * *

២_សេចក្ដីសំរេច

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៧

សេចក្ដីសំរេច លេខ ៥២ សសរ

ស្ដីពី

ការបង្កើតគណៈកម្មការត្រួតពិនិត្យចំណូលថវិកាជាតិ

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-យោងការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី១២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

សម្រេច

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មការត្រួតពិនិត្យចំណូលថវិការដ្ឋ ដែលមានសមាសភាពដូចតទៅ ÷

១-ឯកឧត្ដមឧត្ដមសេនីយ៍ឯក **ញឹម វណ្ណដា** បេសកជនពិសេសរបស់នាយករដ្ឋមន្ត្រីទាំងពីរ ប្រធាន

២-ឯកឧត្ដម **អាយ ខន** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន

៣-ឯកឧត្ដម **សុខ ម៉ារឿន** ទីប្រឹក្សាឯកឧត្ដមនាយករដ្ឋមន្ត្រីទី១ សមាជិក

៤-ឯកឧត្ដម **ឡៅ អ៊ាច ហួ** ទីប្រឹក្សាឯកឧត្ដមនាយករដ្ឋមន្ត្រីទី១ សមាជិក

៥-ឯកឧត្ដម **អាន់ សុផាន់** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៦-ឯកឧត្ដម **ហ៊ុយ ឈឹម** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល សមាជិក

៧-ឯកឧត្ដម **គុច សំ** អនុលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

៨-ឯកឧត្ដម **កែវ សាវ៉ល** អគ្គនាយកនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលកម្ពុជា សមាជិក

៩-លោក **សយ សុខា** ប្រធាននាយកដ្ឋានផែនការនិងសហប្រតិបត្តិការអន្តរជាតិនៃទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

១០-លោក **ហែម ត្រះ...យលាតីតូនី** តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

១១-លោក **ង៉ាល់ ចំនួនតារា** ជំនួយការមេធាវីរាជរដ្ឋាភិបាល សមាជិក

១២-លោក **ម៉ុន ណារី** ជំនួយការឯកឧត្ដម **ញឹម វណ្ណដា** លេខាធិការ

ប្រការ ២ : គណៈកម្មការត្រួតពិនិត្យចំណូលថវិការដ្ឋនេះ មានតួនាទី និងភារកិច្ចដូចតទៅ ÷

១-ត្រួតពិនិត្យទៅលើការប្រមូលចំណូលរបស់ក្រសួង ស្ថាប័ន និងអង្គភាព មានប្រភពចំណូល ហើយត្រូវបង់ចូលថវិការដ្ឋ ។

២-ត្រួតពិនិត្យចំណូលពន្ធ និងអាករពីសកម្មភាពព្រៃឈើ នេសាទ កៅស៊ូ និងផលិតកម្ម អាជីវកម្មផ្សេងៗ ។

៣-ត្រួតពិនិត្យចំណូលពន្ធ និងអាករ ពីអាជីវកម្ម នាំចេញ-នាំចូល និងសេវាកម្មផ្សេងៗ ។

៤_ត្រួតពិនិត្យលើចំណូល ពុំមែនសារពើពន្ធ ។

៥_ធ្វើការសំរបសំរួល ទំនាក់ទំនង និងដោះស្រាយបាតុភាពអសកម្ម លើកវិធានការអនុវត្តក្នុងការបង្ក្រាបបទល្មើសគេងកីបចំណូលថវិការដ្ឋ សំដៅបង្កើនចំណូលថវិការដ្ឋ ក្នុងកាលៈទេសៈពិសេសនេះ ។

៦_ធ្វើអធិការកិច្ច នៅក្រុមហ៊ុនអាកាសចរខេមរភូមិន្ទកម្ពុជា ដោយធ្វើការស្រាវជ្រាវពីស្ថានភាពធ្វើអាជីវកម្មកន្លងមក អោយបានច្បាស់លាស់ ជាពិសេសលើការខាតបង់ ។

៧_បូកសរុបរាយការណ៍ និងលើកវិធានការអនុវត្តតាមដំណាក់កាលនីមួយៗ ជូននាយករដ្ឋមន្ត្រីទាំងពីរ ។

ប្រការ៣ : ក្រសួង ស្ថាប័ន អង្គភាព និងអាជ្ញាធរដែនដី ត្រូវសហការយ៉ាងជិតស្និទ្ធ និងបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ការត្រួតពិនិត្យ និងអធិការកិច្ច របស់គណៈកម្មការត្រួតពិនិត្យចំណូលថវិការដ្ឋ ។

ប្រការ ៤ : សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៥ : គណៈកម្មការនេះមានសិទ្ធិបង្កើតក្រុមជំនួយការសំរាប់ជួយការងារ ។

_គណៈកម្មការនេះ មានទីស្នាក់ការនៅទីស្តីការគណៈរដ្ឋមន្ត្រី ហើយប្រើប្រាស់ថវិកា និងត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន និងសាមីខ្លួន ដែលមានចែងឈ្មោះក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

****

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២៨ ខែ ធ្នូ ឆ្នាំ ២១៩៩៧

៣_សារាចរណែនាំ

សារាចរណែនាំ លេខ ០៧ សរណន
ស្តីពីការរៀបចំបែបបទស្នើសុំគ្រឿងឥស្សរិយយស
នៃព្រះរាជាណាចក្រកម្ពុជា

* * * * *

ចាប់តាំងពីរាជរដ្ឋាភិបាលកម្ពុជាត្រូវបានបង្កើតឡើង ការអនុវត្តន៍តាមទិសដៅភារកិច្ចនយោបាយរបស់រាជរដ្ឋាភិបាលលើវិស័យការពារបូរណភាពទឹកដី អធិបតេយ្យភាព សន្តិភាព អភិវឌ្ឍន៍ប្រទេសជាតិអោយរីកចំរើន មានការចូលរួមយ៉ាងសកម្ម និងច្រើនកុះករពីសំណាក់មន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងប្រជាពលរដ្ឋគ្រប់ស្រទាប់ក្នុងទូទាំងប្រទេស ព្រមទាំងមានការចូលរួមគាំទ្រពីសហគមន៍អន្តរជាតិ ថែមទៀតផង ។

ដើម្បីអនុវត្តព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា និងសេចក្តីសំរេចលេខ ៤៥ សសរ. ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស និងក្នុងគោលដៅលើកទឹកចិត្ត និងថារិកទុកនូវស្នាដៃ គុណបំណាច់របស់វរជន មន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងប្រជាពលរដ្ឋ រួមទាំងជនបរទេសជាមិត្ត ដែលបានខិតខំតស៊ូពុះពារគ្រប់បែបយ៉ាង ធ្វើអោយសំរេចបានលទ្ធផល និងស្នាដៃដូចខាងលើនេះ រាជរដ្ឋាភិបាល សូមធ្វើការណែនាំ ដល់គ្រប់ក្រសួងស្ថាប័ន [illegible]បែបបទនៃការស្នើសុំគ្រឿងឥស្សរិយយសគ្រប់ប្រភេទសំរាប់បំពាក់ជូនអ្នកមានស្នាដៃ និងគុ[illegible]ណាច់ចំពោះប្រទេសជាតិ ដូចមានខ្លឹមសារខាងក្រោមនេះ ÷

១_គ្រប់ក្រសួង ស្ថាប័ន មានសមត្ថកិច្ច ត្រូវបង្កើតអោយមាន «គណៈកម្មការពិនិត្យលក្ខណសម្បត្តិបេក្ខជន ដែលត្រូវស្នើសុំបំពាក់គ្រឿងឥស្សរិយយស» មួយដែលមានថ្នាក់ដឹកនាំក្រសួងស្ថាប័នផ្ទាល់ ជាប្រធានគណៈកម្មការ និងថ្នាក់ដឹកនាំ អង្គភាពសំខាន់ៗ ក្រោមឱវាទក្រសួងស្ថាប័ន ជាសមាជិក ។ គណៈកម្មការនេះ មានភារកិច្ចពិនិត្យលក្ខណសម្បត្តិវរជន មន្ត្រី រាជការក្រោម ឱវាទសំរាប់ជ្រើសរើសជាបេក្ខជន ស្នើសុំគ្រឿងឥស្សរិយយសទៅតាមប្រភេទ និងវិស័យ

ការងារ ដូចមានចែងក្នុងព្រះរាជក្រឹត្យ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ដែលបានជូនភ្ជាប់មកជាមួយនេះស្រាប់ ។ ក្រោយពេលគណៈកម្មការពិនិត្យជ្រើសរើស និងមានការឯកភាពពីប្រធានស្ថាប័នរួចហើយ ក្រសួងស្ថាប័នត្រូវផ្ញើសំណើ និងបញ្ជីឈ្មោះបេក្ខជន ដោយភ្ជាប់មកជាមួយនូវទឡ្ហីករណ៍ (របាយការណ៍អំពីគុណបំណាច់ និងស្នាដៃរបស់បេក្ខជនម្នាក់ៗ សរសេរដោយបេក្ខជនផ្ទាល់) ផ្ញើមក «គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយសនៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងដាក់ជូនរាជរដ្ឋាភិបាលសំរេច ។

២_វរជនមន្ត្រី រាជការ ដែលមានស្នាដៃ និងគុណបំណាច់ខ្ពស់ ចំពោះប្រទេសជាតិ ទៅតាមវិស័យការងារនីមួយៗ មុននឹងត្រូវបានជ្រើសរើសជាបេក្ខជនសំរាប់ស្នើគ្រឿងឥស្សរិយយស ត្រូវមានលក្ខណសម្បត្តិធំៗ ៤ចំណុច ដូចខាងក្រោម ÷

ក_មានសីលធម៌រស់នៅ ស្អាតស្អំ មិនប្រព្រឹត្តអំពើផ្ទុយនឹងច្បាប់រដ្ឋ

ខ_មានមនសិការវិជ្ជាជីវៈខ្ពស់ សកម្មការងារ ឧស្សាហ៍ព្យាយាម

គ_មានសាមគ្គីភាព និងទំនាក់ទំនងល្អ ជិតស្និទ្ធជាមួយមន្ត្រី រាជការ និងមហាជនទូទៅ

ឃ_មានស្មារតីស្នេហាជាតិខ្ពស់

ផ្អែកលើលក្ខណសម្បត្តិធំៗទាំង៤នេះ គណៈកម្មការពិនិត្យលក្ខណសម្បត្តិបេក្ខជនរបស់ក្រសួង ស្ថាប័ននីមួយៗត្រូវលើកលក្ខណៈវិនិច្ឆ័យជាក់ស្តែងស្របតាមសកម្មភាពការងាររបស់ក្រសួង ស្ថាប័នរបស់ខ្លួន ។

៣_របាយការណ៍ស្តីពីស្នាដៃ និងគុណបំណាច់របស់បេក្ខជនម្នាក់ៗ ត្រូវបញ្ជាក់អោយបានច្បាស់នូវចំណុចដូចខាងក្រោម ÷

_ឈ្មោះ ភេទ អាយុ

_រយៈពេលបំពេញការងាររដ្ឋ (ចំពោះមន្ត្រី រាជការ)

_វិជ្ជាជីវៈ និងមុខងារបច្ចុប្បន្ន

_ទំហំស្នាដៃ និងគុណបំណាច់ចំពោះប្រទេសជាតិ បើអាចគិតជាទឹកប្រាក់ សូមបញ្ជាក់អោយបានច្បាស់លាស់ ។

៤_វរជន មន្ត្រី រាជការ ដែលបំពេញការងារក្នុងវិស័យនិមួយៗ អាចនឹងទទួលបាន គ្រឿងឥស្សរិយយសផ្សេង ខុសពីមុខជំនាញរបស់សាមីខ្លួនបាន បើសិនជាស្នាដៃ និងគុណបំណាច់របស់ខ្លួនបំរើអោយវិស័យផងទៀត ។

ឧទាហរណ៍ : ជនស៊ីវិល អាចនឹងទទួលមេដាយការពារជាតិបាន បើសិនសាមីខ្លួនមាន គុណបំណាច់ក្នុងការជួយឧបត្ថម្ភគាំទ្រដល់កិច្ចការការពារជាតិ ។ល។

៥_ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចពិនិត្យវាយតំលៃការ ងាររបស់បណ្តាបុគ្គលិកអង្គទូត និងតំណាងប្រទេសជាមិត្ត ព្រមទាំងតំណាងអង្គការអន្តរជាតិនានា ដែលបំពេញភារកិច្ច នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយមានស្នាដៃ និងគុណបំណាច់ល្អប្រសើរ បំរើអោយផលប្រយោជន៍ប្រជារាស្ត្រខ្មែរ ដើម្បីស្នើសុំបំពាក់មេដាយសហមេត្រី នៅមុនពេលបញ្ចប់ អាណត្តិនិមួយៗ ប៉ុន្តែត្រូវបានការឯកភាពពីភាគីមិត្តជាមុនសិន មុននឹងផ្ញើមកទីស្តីការគណៈ រដ្ឋមន្ត្រី ។

៦_ចំពោះបែបបទនៃការស្នើសុំមេដាយស្ថាបនាជាតិ ដែលបានអនុវត្តកន្លងមក តាម ខ្លឹមសារអនុក្រឹត្យលេខ ១៥អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ ត្រូវរក្សាការអនុវត្តន៍ដដែល ដោយគ្រាន់តែប្តូរឈ្មោះពី ÷

_មេដាយស្ថាបនាជាតិថ្នាក់លេខ១ ទៅជា មេដាយ មាសស្ថាបនាជាតិ

_មេដាយស្ថាបនាជាតិថ្នាក់លេខ២ ទៅជា មេដាយ ប្រាក់ស្ថាបនាជាតិ

_មេដាយស្ថាបនាជាតិថ្នាក់លេខ៣ ទៅជា មេដាយ សំរិទ្ធស្ថាបនាជាតិ

ដើម្បីអោយស្របតាមព្រះរាជក្រឹត្យថ្មីតែប៉ុណ្ណោះ ។

៧_ចំនួនបេក្ខជនប្រចាំឆ្នាំនៃបណ្តាក្រសួង ស្ថាប័ននីមួយៗ ដែលត្រូវស្នើសុំគ្រឿងឥស្សរិ យយសគ្រប់ប្រភេទ ត្រូវកំណត់មិនអោយលើសពី ១០ភាគរយ នៃចំនួនក្របខ័ណ្ឌសរុបរបស់ ក្រសួងស្ថាប័នឡើយ ។

_បុគ្គលដែលមានស្នាដៃល្អឆ្នើម អាចត្រូវស្នើបំពាក់មេដាយសេនាជ័យសិទ្ធិបាន លុះ ត្រាតែបុគ្គលនោះធ្លាប់បានទទួលមេដាយការពារជាតិយ៉ាងតិចបីដងរួចហើយ ។

_ចំនួនបេក្ខជនដែលត្រូវស្នើសុំគ្រឿងឥស្សរិយយសក្នុងលំដាប់ឋានានុក្រមខ្ពស់ ត្រូវ អោយតិចជាងចំនួនបេក្ខជនដែលត្រូវស្នើសុំគ្រឿងឥស្សរិយយសក្នុងលំដាប់ឋានានុក្រមទាបជាង។

ក្នុងដំណាក់ដំបូង គណៈកម្មការរបស់ក្រសួងស្ថាប័ននិមួយៗត្រូវស្នើឥស្សរិយយសពីថ្នាក់ទាបសិន មុននឹងឈានទៅដល់ថ្នាក់ខ្ពស់ជាបន្តបន្ទាប់ ។

៨_បណ្តាក្រសួង ស្ថាប័ន មានសមត្ថកិច្ច ដែលមានគំរោងស្នើសុំគ្រឿងឥស្សរិយយស ត្រូវបញ្ជូនសំណើ និងបញ្ជីឈ្មោះបេក្ខជនអោយមកដល់ទីស្តីការគណៈរដ្ឋមន្ត្រីយ៉ាងយូរបំផុតត្រឹម ថ្ងៃទី ៣០ ខែ កញ្ញា នៃឆ្នាំនិមួយៗ ដើម្បីអាចបូកសរុប ពិនិត្យ និងសំរេច ជូនគ្រឿងឥស្សរិយយស នាឱកាសដំណាច់ឆ្នាំ ។

រាជរដ្ឋាភិបាល សង្ឃឹមជឿជាក់យ៉ាងមុតមាំថា ក្រោយពេលទទួលបានសារាចរណែនាំ នេះទៅ គ្រប់ក្រសួង ស្ថាប័ន គ្រប់ជាន់ថ្នាក់ នឹងចាត់ចែងអនុវត្តប្រកបដោយស្មារតីយកចិត្តទុកដាក់ យុត្តិធម៌ ស្មើភាព សំដៅរក្សាអោយបាននូវសុក្រឹត្យភាព និងតម្លៃនៃគ្រឿងឥស្សរិយយសរបស់ជាតិ យើង ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

****

៥_ប្រកាស

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៩៧

លេខ ០២ប្រក.

នាយករដ្ឋមន្ត្រីទី១ សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

នាយករដ្ឋមន្ត្រីទី២ សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

_បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម** សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ
- យោងតំរូវការចាំបាច់នៃការងារ

សំរេច

ប្រការ ១ : ប្រគល់សិទ្ធិជូនឯកឧត្តមអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការគ្រប់គ្រង «វិមានរដ្ឋាភិបាល» ដែលជាទីស្តីការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្នុងការគ្រប់គ្រងថវិកានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

ប្រការ ២ : អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ និងគ្រប់ផ្នែកចំណុះក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១
សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
ហត្ថលេខានិងត្រា
អ៊ុង ហួត

នាយករដ្ឋមន្ត្រីទី២
សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
ហត្ថលេខានិងត្រា
ហ៊ុន សែន

III _ការងាររបស់ក្រសួង

១_ទីស្តីការគណៈរដ្ឋមន្ត្រី

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាស លេខ ១៧២ ប្រក.

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤
- យោងតាមការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : ត្រូវបានតែងតាំងលោកស្រី **ឈឹម គី** ជាអនុប្រធាននាយកដ្ឋានតំកល់ឯកសារ នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ២ : ប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច នាយកដ្ឋានតំកល់ឯកសារ ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ស្តីទី

ហត្ថលេខានិងត្រា

សុខ អាន ឈាងី តាន់

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាស លេខ ១៧៤ ប្រក.

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * * *

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤
- យោងតាមការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : ត្រូវបានតែងតាំងលោកស្រី **កៅ សារីន** ជាប្រធានការិយាល័យទទួលបន្ទុកការ ផលផល សំភា សិកម្ម និងរដ្ឋបាល របស់នាយកដ្ឋានកសិកម្ម នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ២ : ប្រធាននាយកដ្ឋានបុគ្ យកដ្ឋានរដ្ឋបាល នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច នាយកដ្ឋានកសិកម្ម ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ស្តីទី

ហត្ថលេខានិងត្រា

សុខ អាន　　**ឈាងី តាន់**

* * * *

២_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាស លេខ ៣២០/៩៧ ពម.ប្រក.

ស្ដីពីការតែងតាំងមន្ត្រីរាជការ ក្រសួងពត៌មាន

* * * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស.រកម ០១៩៦_១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងពតិមាន
- យោងតាមសំណើរបស់នាយកដ្ឋានសំភារៈ និងបរិក្ខារ
- ពិនិត្យលើលក្ខណសម្បត្តិ និងសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងលោក **សៀង ស៊ីម៉េត** ជាអនុប្រធានការិយាល័យបច្ចេកទេស នាយកដ្ឋានសំភារៈ និងបរិក្ខារ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងពតិ ។

ប្រការ ២ : ឯកឧត្តម អគ្គនាយក រដ្ឋបាល និងហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ លោកប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានសំភារៈ និងបរិក្ខារ ប្រធាននាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញកិច្ច និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាស លេខ ៣២១/៩៧ ពម.ប្រក.

ស្តីពីការតែងតាំងមន្ត្រីរាជការ

****

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស.រកម ០១៩៦-១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពតិមាន
- យោងតាមសំណើរបស់នាយកដ្ឋានឯកសារ និង បណ្ណាល័យ
- ពិនិត្យលើលក្ខណសម្បត្តិ និងសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការចំនួន ២រូប ជាប្រធានការិយាល័យ នាយកដ្ឋានឯកសារ និង បណ្ណាល័យ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងពតិមាន ដូចមានរាយនាមខាងក្រោមនេះ ៖

១-កញ្ញា **ឃួន តារា** ប្រធានការិយាល័យបណ្ណាល័យ

២-លោក **គុយ សុជាតិ** ប្រធានការិយាល័យឯកសារ

ប្រការ ២ : ឯកឧត្តម អគ្គនាយក រដ្ឋបាល និងហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញកិច្ច និងសាមីខ្លួនក្នុងប្រការ១ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាស លេខ ៤១១ ប្រក.សក.ហវ

ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

* * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន

សំរេច

ប្រការ ១ : ប្រការ ២ នៃប្រកាសលេខ ៣៩១ ប្រក.សក.ហវ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ស្តីពីការផ្ទេរទីតាំង និងអគារទាំងអស់របស់សាលាមធ្យមសិក្សាបច្ចេកទេសសាធារណការនិងដឹកជញ្ជូន ជូនទៅអគ្គនាយកដ្ឋានដឹកជញ្ជូនប្រើប្រាស់ជាការិយាល័យ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ២ : អគ្គនាយកដ្ឋានដឹកជញ្ជូន ត្រូវផ្ទេរទៅនៅក្នុងអគារបីខ្នង នៃសាលាមធ្យមសិក្សាបច្ចេកទេសសាធារណការនិងដឹកជញ្ជូន ក្នុងរយៈពេលដែលនឹងរកដំណោះស្រាយជាក់ស្តែង សាងសង់ទីស្នាក់ការអចិន្ត្រៃយ៍ថ្មី សមស្របទៅនិងទំហំការងារប្រចាំ និងនាអនាគតកាល ។

ប្រការ ៣ : ឯកឧត្តមប្រធានគណៈកម្មការជាតិទន្លេមេគង្គ ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុកការងារដឹកជញ្ជូន លោកនាយកខុទ្ទកាល័យ នាយការិយាល័យគណនេយ្យហិរញ្ញវត្ថុ និងជំរះបញ្ជី លោកប្រធានមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស លោកនាយកសាលាមធ្យមសិក្សាបច្ចេកទេសសាធារណការនិងដឹកជញ្ជូន ត្រូវទទួលបន្ទុករៀងៗខ្លួន អនុវត្តន៍នូវប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់សំរេចបានលទ្ធផលល្អប្រសើរ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន
ហត្ថលេខានិងត្រា
អ៊ឹង គៀត

* * * *

៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាស លេខ ៨៨២ អយក.ប្រក

ស្តីពីការពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យទាលរទៀ
ទៅជាវិទ្យាល័យ ហ៊ុន សែន «ទាលរទៀ» ស្ថិតក្នុងសង្កាត់
ទាលរទៀ ខ័ណ្ឌទាលរទៀ ក្រុងព្រះសីហនុ

* * * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧៩៦/៩២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញសារាចរណែនាំ លេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៨៣ ស្តីពីការបើកសាលាមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើរបស់មន្ទីរអប់រំ យុវជន និងកីឡា ក្រុងព្រះសីហនុ លេខ ២៥០ អយក.នស ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៧ ដោយមានចំណារឯកភាពពីអភិបាលក្រុងព្រះសីហនុ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និងមធ្យមសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយពង្រីក និងប្តូរឈ្មោះ **អនុវិទ្យាល័យ ទារសពេញ** បច្ចុប្បន្នទៅជា **វិទ្យាល័យ ហ៊ុន សែន «ទារសពេញ»** ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក_នាយករងនៃវិទ្យាល័យ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមធ្យមសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការនិងហិរញ្ញកិច្ច នៃក្រសួងអប់រំ យុវជន និង

កីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ក្រុងព្រះសីហនុ និងនាយកវិទ្យាល័យ សាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សាឃាន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាស លេខ ៨៨៤ អយក.ប្រក

ស្តីពីការពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ កំពង់ពោធិ៍

ទៅជាវិទ្យាល័យ ហ៊ុន សែន «កំពង់ពោធិ៍» ស្ថិតក្នុងស្រុក

កំពង់ពោធិ៍ ខេត្តស្វាយរៀង

* * * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ

-បានឃើញសារាចរណែនាំ លេខ ៦៦ .អ.ប.ចទម ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៨៣ ស្តីពីការបើកសាលាមធ្យមសិក្សាកំរិត១_កំរិត២

-យោងលិខិតស្នើរបស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៧ ដោយមានយោបល់ឯកភាពពីអភិបាលខេត្តស្វាយរៀង

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយពង្រីក និងប្តូរឈ្មោះ **អនុវិទ្យាល័យ កំពង់រោទិ៍** បច្ចុប្បន្នទៅជា **វិទ្យាល័យ ហ៊ុន សែន «កំពង់រោទិ៍»** ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក_នាយករងនៃវិទ្យាល័យ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការនិងហិរញ្ញកិច្ច នៃក្រសួងអប់រំ យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង និងនាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សាមាន

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាស លេខ ៨៨៥ អយក.ប្រក

ស្តីពីការបើកវិទ្យាល័យ «សុខាផល្លី» ឧបសម្ព័ន្ធ

វិទ្យាល័យកំពង់ស្ពឺ ផ្តាច់ពី វិទ្យាល័យកំពង់ស្ពឺ

* * * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញសារាចរណែនាំ លេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៨៣ ស្តីពីការបើកសាលាមធ្យមសិក្សាកំរិត១–កំរិត២
- យោងលិខិតស្នើរបស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ស្ពឺ លេខ ៣៤០ អយក. ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩៧ ដោយមានចំណាប់ឯកភាពរបស់អភិបាលខេត្តកំពង់ស្ពឺ ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើក **វិទ្យាល័យ សុខាផល្លី** ផ្តាច់ពី **វិទ្យាល័យ កំពង់ស្ពឺ** ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក_នាយករងនៃវិទ្យាល័យ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការនិងហិរញ្ញកិច្ច នៃក្រសួងអប់រំ យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ស្ពឺ និងនាយកវិទ្យាល័យ សាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សារុន

****

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាស លេខ ៨៨៦ អយក. ប្រក

ស្ដីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅសិក្សាសង្គម

«សំរាប់សិស្សថ្នាក់ទី៤»

* * * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានពិនិត្យលិខិតឧទ្ទេ[illegible] លេខ ៣១៨ អយក.ខទន ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្ដីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការពិនិត្យខ្លឹមសារសៀវភៅសិក្សាសង្គមថ្នាក់ទី៤ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅសិក្សាសង្គមសំរាប់សិស្សថ្នាក់ទី៤ ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការសិក្សាសង្គមបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា និងរៀបរៀងដោយអ្នកស្រី **យិន ចាន់ថា** ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំនេះទូទៅ ។

ប្រការ ២ : មន្ទីរនាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយបណ្ណាល័យ នាយកដ្ឋានចំណេះទូទៅនិងមត្តេយ្យសិក្សា មានភារកិច្ចអនុវត្តសេចក្តីប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

តា សាហាន

* * * *

៥_និស្ស័ការរដ្ឋមន្ត្រីក្រសួងសុខាភិបាល

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាស លេខ ៣៦/៩៧ សនក្រ.

ស្តីពី

ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីសេវាវេជ្ជសាស្ត្រ

ឱសថវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ

* * * *

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១_១១_១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤_០១_១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ៦៧ អនក្រ. បក ចុះថ្ងៃទី ២២_១០_១៩៩៧ ស្តីពីការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល

-បានឃើញសេចក្តីសំរេចលេខ ៥០ សសរ. ចុះថ្ងៃទី ០៥-៤-១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការបង្កើតកន្លែងពិនិត្យព្យាបាលជំងឺ ព្យាបាលជំងឺមាត់ធ្មេញ ស្រោបធ្មេញ ដាក់ធ្មេញ មន្ទីរសម្ភព មន្ទីរពិសោធន៍វេជ្ជសាស្ត្រ និងមន្ទីរពាហុព្យាបាលជំងឺឯកជន

-បានឃើញសេចក្តីសំរេចនៃកិច្ចប្រជុំ ចុះថ្ងៃទី ០៤-១១-១៩៩៧ របស់ក្រសួងសុខាភិបាល

សំរេច

ប្រការ ១ : ការផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជកម្មអំពីសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រត្រូវហាមឃាត់ជាដាច់ខាត ។

ប្រការ ២ : វេជ្ជបណ្ឌិត គ្រូពេទ្យ និងឱសថការី ដែលបានទទួលច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាលត្រូវទទួលខុសត្រូវក្នុងវិជ្ជាជីវៈរបស់ខ្លួន ដូចមានចែងក្នុងប្រការ១ ។

ប្រការ ៣ : ក្នុងករណីល្មើសនឹងប្រកាសនេះ វេជ្ជបណ្ឌិត គ្រូពេទ្យ ឬ ឱសថការី ដែលជាអ្នកទទួលខុសត្រូវ ទទួលការព្រមាន ឬ ត្រូវដកហូតច្បាប់អនុញ្ញាត ។

ប្រការ ៤ : ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រការ ៥ : ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ អគ្គាធិការដ្ឋានមន្ទីរសុខាភិបាលគ្រប់ខេត្ត-ក្រុង ព្រមទាំងសាមីជនអ្នកទទួលខុសត្រូវ ត្រូវទទួលភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

វេជ្ជ . ឈា ថាំង

* * * *

៦_ទីស្តីការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាស លេខ ២១២ ប.ទ.ប្រក.

ស្តីពីការបង្កើតមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ក្រុងប៉ៃលិន

* * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១_១១_១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកត/១០៩៤/៥៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១_១០_៩៤ ស្តីពីការកែសំរួលរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០_០៧_១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើនូវច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/ ០៧៩៧/១៤៤ ចុះថ្ងៃទី ៣១_៧_៩៧ ស្តីពីការបង្កើតក្រុងប៉ៃលិន
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧_៨_៩៧ ស្តីពីការកែសំរួលរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញលិខិតលេខ ៥៧/១០ ក.ប.ល ឆ្នាំ ១៩៩៧ របស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងប៉ៃលិន

-បានឃើញការងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : ត្រូវបានបង្កើតមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ទីក្រុងប៉ៃលិន ដែលមានទីតាំងនៅទីក្រុងប៉ៃលិន ។

ប្រការ ២ : ត្រូវបានបង្កើតមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ទីក្រុងប៉ៃលិន ជាអង្គភាពរដ្ឋបាលសេដ្ឋកិច្ច ដែលដឹកនាំដោយបឋិត្ថាហកៈមួយរូប និងអមដោយបឋិត្ថាហកៈរងមួយចំនួន ជាជំនួយការ ។

ប្រការ ៣ : ខុទ្ទកាល័យ អធិការដ្ឋាន នាយកដ្ឋានផែនការគណនេយ្យ-ហិរញ្ញវត្ថុ នាយកដ្ឋានប្រៃសណីយ៍ នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ និងមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ទីក្រុងប៉ៃលិន ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខានិងត្រា

សូ ឃុន

* * * * *

៧-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៧

សេចក្តីសំរេច លេខ ៦៩៣ សសរ.មស.ក្រខ

ស្តីពីការបែងចែកនិស្សិតចំនួន ២៧នាក់ ដែលទើបបញ្ចប់ការសិក្សាពីបរទេស

* * * *

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២.នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស.រកម ០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងលិខិតលេខ ៣១៩ សជណ.អវ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : អ្នកបច្ចេកទេសថ្នាក់ឧត្ដមចំនួន ២៦នាក់ និងថ្នាក់មធ្យមចំនួន ១នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស ត្រូវបានបែងចែកអោយទៅបំរើការងារនៅក្រសួង-ស្ថាប័ន មួយចំនួន ដូចមានក្នុងតារាងឧបសម្ព័ន្ធនៃសេចក្ដីសំរេចនេះ ។

ប្រការ ២ : ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះ ដើម្បីរៀបចំការងារអោយត្រូវតាមមុខជំនាញ និងផ្ដល់បៀវត្សជូនសាមីជន ចាប់ពីថ្ងៃដែលបានចូលបំរើការងារជាផ្លូវការ ។

ប្រការ ៣ : សេចក្ដីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ប្រាក់ សុខ

តារាងឧបសម្ព័ន្ធនៃសេចក្ដីសំរេចលេខ ៦៩៧ សសរ.ក្រខ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧
ស្ដីពីការបែងចែកនិស្សិតចំនួន ២៧នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស

ល.រ	នាមត្រកូល និងនាមខ្លួន	ភេទ	ថ្ងៃ ខែ ឆ្នាំ កំណើត	អង្គភាព ដើម	មុខវិជ្ជាបច្ចេកទេស	ប្រទេសបណ្ដុះបណ្ដាល	កំរិតបណ្ដុះបណ្ដាល	បៀវត្ស	អង្គភាពទទួលបំពេញការងារ
១	ថៃ ជុន	ប	១៨_០១_៧២	សិស្ស	ផែនការសេដ្ឋកិច្ចនិងសង្គម	សូវៀត	ឧត្ដម	៩០% ឋ ១	ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
២	សុខ សុបុន្ន	ស	០៩_១០_៧០	សិស្ស	ភាសា_បកប្រែអង់គ្លេសរុស្ស៊ី	សូវៀត	ឧត្ដម	៩០% ឋ ១	ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
៣	មាឃ ប្រាថ្នា	ប	០៦_៧_៧៤	សិស្ស	សេដ្ឋកិច្ចនិងគ្រប់គ្រងផ្លូវទឹក	សូវៀត	ឧត្ដម	៩០% ឋ ១	ក្រសួងសាធារណៈការនិងដឹកជញ្ជូន
៤	ម៉ាន់ សុវត្ថិ	ប	២០_០១_៦៧	សិស្ស	វេជ្ជសាស្ត្រទូទៅ	សូវៀត	ឧត្ដម	៩០% ឋ ១	ក្រសួងសុខាភិបាល
៥	នួ ម៉ានិត	ប	០៩_៤_៧១	សិស្ស	ស្ថាបត្យកម្ម	សូវៀត	ឧត្ដម	៩០% ឋ ១	ទីស្ដីការគណៈរដ្ឋមន្ត្រី
៦	នុត នីម៉ង់	ប	១៥_៤_៧១	សិស្ស	រៀបចំក្រុងនិងសំណង់	សូវៀត	ឧត្ដម	៩០% ឋ ១	ក្រសួងសាធារណៈការនិងដឹកជញ្ជូន
៧	អ៊ុំ សារ៉ុ	ប	១៧_៣_៦៦	បុគ្គលិក	ស្ថាបត្យកម្ម	វៀតណាម	ឧត្ដម	[illegible]	ក្រសួងសាធារណៈការនិងដឹកជញ្ជូន
៨	ឡៀវ សៅ	ប	១០_០២_៦៨	បុគ្គលិក	ស្ថាបត្យកម្ម	វៀតណាម	ឧត្ដម	[illegible]	ក្រសួងសាធារណៈការនិងដឹកជញ្ជូន
៩	ធួន សុវណ្ណ	ប	០៧_៤_៧០	សិស្ស	គ្រឿងយន្ត	វៀតណាម	ឧត្ដម	៩០% ឋ ១	ក្រសួងសាធារណៈការនិងដឹកជញ្ជូន
១០	ឡៀប ពៅ	ស	២០_៦_៧៣	សិស្ស	និសថសាស្ត្រ	វៀតណាម	ឧត្ដម	៩០% ឋ ១	ក្រសួងសុខាភិបាល •
១១	រ៉ែន សុវណ្ណរិទ្ធ	ប	២២_០១_៦៩	សិស្ស	បសុព្យាបាល	វៀតណាម	ឧត្ដម	៩០% ឋ ១	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
១២	អ៊ុក សំអួន	ប	០១_០១_៧០	សិស្ស	មច្ឆវប្បកម្ម	វៀតណាម	ឧត្ដម	៩០% ឋ ១	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
១៣	ញ៉ុង ផា	ប	២៣_០២_៧៣	សិស្ស	បសុព្យាបាល	វៀតណាម	ឧត្ដម	៩០% ឋ ១	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
១៤	ព្រំ វិមាន	ប	០១_០១_៧១	សិស្ស	បសុព្យាបាល	វៀតណាម	ឧត្ដម	៩០% ឋ ១	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
១៥	ស៊ុន នីផារ៉ូ	ប	២៤_៤_៧៤	សិស្ស	ជួសជុលផ្លូវថេភ្លើង_សំណង់	សូវៀត	មធ្យម	៩០%ឋ១	ក្រសួងសាធារណៈការនិងដឹកជញ្ជូន
១៦	សន សុភាព	ប	២៨_១១_៦៧	សិស្ស	ហិរញ្ញវត្ថុ	ហុងគ្រី	ឧត្ដម	៩០% ឋ ១	ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
១៧	សេម ស៊ូល	ប	០៣_៥_៧២	សិស្ស	សេដ្ឋកិច្ចផលផល	វៀតណាម	ឧត្ដម	៩០% ឋ ១	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
១៨	ខុ ពុយ	ប	០៧_៤_៧១	សិស្ស	បសុព្យាបាល	វៀតណាម	ឧត្ដម	៩០% ឋ ១	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
១៩	ពេជ អំបូពស្ស	ប	១០_១២_៧៤	សិស្ស	គ្រប់គ្រងសេដ្ឋកិច្ចទេសចរណ៍	វៀតណាម	ឧត្ដម	៩០% ឋ ១	ក្រសួងទេសចរណ៍

២០	ជួ ណា	ប	០៧-៥-៧២	សិស្ស	គ្រប់គ្រងសេដ្ឋកិច្ចទេសចរណ៍	វៀតណាម	ឧត្តម	៩០% អ ១	ក្រសួងទេសចរណ៍
២១	មាស ឧត្តមនី	ប	០៥-៤-៧៣	សិស្ស	គ្រប់គ្រងសេដ្ឋកិច្ចទេសចរណ៍	វៀតណាម	ឧត្តម	៩០% អ ១	ក្រសួងទេសចរណ៍
២២	សេង ធួក	ប	១០-៤-៦៨	សិស្ស	ពាណិជ្ជកម្មក្រៅប្រទេស	វៀតណាម	ឧត្តម	៩០% អ ១	ក្រសួងពាណិជ្ជកម្ម
២៣	សៀង ហួម	ប	១៧-៥-៧១	សិស្ស	ពាណិជ្ជកម្មក្រៅប្រទេស	វៀតណាម	ឧត្តម	៩០% អ ១	ក្រសួងពាណិជ្ជកម្ម
២៤	ភង់ ពុទ្ធារ៉ា	ប	០២-៥-៧២	សិស្ស	ពាណិជ្ជកម្មក្រៅប្រទេស	វៀតណាម	ឧត្តម	៩០% អ ១	ក្រសួងពាណិជ្ជកម្ម
២៥	ទូស សាផា	ប	០៨-៧-៧០	សិស្ស	ពាណិជ្ជកម្មក្រៅប្រទេស	វៀតណាម	ឧត្តម	៩០% អ ១	ក្រសួងពាណិជ្ជកម្ម
២៦	សៀ យូ	ប	០១-០១-៧០	សិស្ស	ពាណិជ្ជកម្មក្រៅប្រទេស	វៀតណាម	ឧត្តម	៩០% អ ១	ក្រសួងពាណិជ្ជកម្ម
២៧	ជីម ផល្លីទ្ធ	ប	០១-០២-៧២	សិស្ស	ពាណិជ្ជកម្មក្រៅប្រទេស	វៀតណាម	ឧត្តម	៩០% អ ១	ក្រសួងពាណិជ្ជកម្ម

បានបញ្ចប់បញ្ជីនេះត្រឹមចំនួន « ២៧ » ប្តូរពាក្យពីរពាក្យប៉ុណ្ណោះ ។

រដ្ឋលេខាធិការ

ហត្ថលេខា

ប្រាក់ សុខុ

បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី

លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២៧៥០ រៀល